**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ការអនុវត្តស្មុំកូនក្រោមច្បាប់ នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ :
និស្សិតឈ្មោះ កញ្ញា **តុប ស្រីភ័ស**
លោក **តាំង ភាហ្វុខ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តសុំកូនក្រោមច្បាប់ នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ :

និស្សិតឈ្មោះ កញ្ញា **តុប ស្រីភ័ស**

លោក **តាំង ភាហុង**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ឪពុកអ្នកម្តាយ ដែលបានបង្កើតរូបរាងកាយ និងខំចិញ្ចឹមបីបាច់ថែរក្សាកូនៗគ្រប់គ្នាមិនឱ្យមានចិត្តសៅម៉ងម្តងណាឡើយ។ ហើយឱ្យបានសិក្សារៀនសូត្រ តាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រនេះ ដោយពេលខ្លះកំពុងខ្វះខាតលុយកាក់ប៉ុណ្ណាក៏ដោយ លោកទាំងពីរខិតខំរិះរកគ្មានពេលសម្រាក និងនៅតែលើកទឹកចិត្តកូនឱ្យខិតខំរៀនសូត្រដើម្បីក្លាយទៅជាធនធានល្អនៅក្នុងសង្គម។ ជាចុងក្រោយ កូនសុំប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ គ្រប់ប្រការចូលកើតមានការរីកចម្រើន និងមានសុខភាពល្អជារៀងរហូត។

ព្រមទាំងថ្លែងអំណរគុណ ដល់គណៈគ្រប់គ្រងសាលកវិទ្យាល័យ រួមទាំងសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំបង្រៀនក៏ដូចជា ផ្ទេរនូវចំណេះដឹងគ្រប់ផ្នែកដល់យើងទាំងអស់គ្នា។

ជាពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បណ្ឌិត **ទេព សុខ** ដែលជាសាស្រ្តាចារ្យនៃសាកលភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានជំរុញដល់ការសិក្សាស្រាវជ្រាវនូវចំណេះដឹងផ្សេងៗទៀតផងដែរ។ សូមជូនពរលោកគ្រូ មានសុខភាព និងសម្រេចជោគជ័យគ្រប់ភារកិច្ចទាំងអស់ក្នុងជីវិត។

ជាចុងក្រោយ ក្រុមខ្ញុំបាទ សូមអរគុណច្រើនចំពោះសមាជិកក្រុមទាំងអស់ ដែលបានចូលរួមសាមគ្គីគ្នាយ៉ាងមុតមាំ ដើម្បីសិក្សាស្រាវជ្រាវរកឯកសារ ដែលមានប្រភពច្បាស់លាស់ ដោយបានជោគជ័យ។ ខ្ញុំសង្ឃឹមជឿជាក់ថា ការសិក្សារបស់យើងគ្រប់គ្នា និងទទួលបានលទ្ធផលល្អនាថ្ងៃអនាគត និងក្លាយជាធនធានល្អដែលសង្គមជាតិរបស់យើងគ្រប់ៗគ្នាតរៀងទៅ។

# **អារម្ភកថា**

កុមារ គឺជាទំពាំងដែលនឹងស្នងឫស្សីនៅថ្ងៃអនាគត។ កិច្ចការពារផលប្រយោជន៍កុមារ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គម។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ពិតជាបានខ្វាយខ្វល់ពីសិទ្ធិរបស់ប្រជាពលរដ្ឋរបស់ខ្លួន ជាពិសេសគឺស្ត្រី និងកុមារ។ យើងត្រូវតែធានាថាកុមារគ្រប់រូបអាចទទួលបានសិទ្ធគ្រប់យ៉ាង ដើម្បីការរីកចម្រើន និងការអភិវឌ្ឍខ្លួន នៅក្នុងគ្រួសារមួយដែលល្អ ប្រកបដោយភាពកក់ក្ដៅ និងគ្មានការបំពាន។ ផ្ទុយទៅវិញ បើកុមារនោះរស់នៅក្នុងគ្រួសារដែលមិនល្អ មិនមានការមើលថែពីឪពុកម្ដាយ ឬទទួលរងអំពើហិង្សាទៀតនោះ វានឹងធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ និងសិទ្ធកុមារ ដែលជាកត្តាធ្វើឱ្យមានការប៉ះពាល់ដល់ការរីកចម្រើនធំធាត់របស់កុមារទៀតផង។

ដូច្នេះ ក្រុមខ្ញុំបាទលើកយកប្រធានបទមួយស្ដីពី « **ការអនុវត្តសុំកូនក្រោមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា** » ដែលជាបញ្ហាគួរឱ្យកត់សម្គាល់ផងដែរ ព្រោះថាប្រជាពលរដ្ឋមួយចំនួននៅពុំទាន់យល់ពីការសុំកូននៅប្រទេសយើងនៅឡើយ។ ច្បាប់ដែលមានចែងពីការសុំកូនពិតជាមានសារសំខាន់ខ្លាំងណាស់ នៅក្នុងការធានាផលប្រយោជន៍ និងសិទ្ធិកុមារ ដូច្នេះយើងគួរគប្បីសិក្សាស្វែងយល់ឱ្យបានលម្អិត។

ក្រុមខ្ញុំបាទ រួមជាមួយសាស្ត្រាចារ្យណែនាំ បានប្រឹងប្រែងអស់ពីលទ្ធភាព ក្នុងការស្រាវជ្រាវនិងចង់ក្រងសរសេរអត្ថបទសារណានេះឱ្យបានល្អបំផុត។ ក្រុមខ្ញុំសង្ឃឹមថាយ៉ាងមុតមាំថា តាមរយៈការសិក្សានិងបកស្រាយប្រធានបទនេះ នឹងស្រាយចម្ងល់បានជាប្រយោជន៍ដល់បងប្អូននិស្សិត ក៏ដូចជាប្រជាពលរដ្ឋទាំងអស់។ ជាមួយគ្នានេះដែរ ក្រុមខ្ញុំបាទសូមអភ័យទោសរាល់កំហុសឆ្គង ចំណុចត្រង់ណាដែល ក្រុមខ្ញុំបាទធ្វើការស្រាវជ្រាវមានភាពខ្វះចន្លោះ ឬ មិនទាន់គ្រប់គ្រាន់ និងកំហុសអក្ខរាវិរុទ្ធនានា ដែលកើតមានឡើងដោយឯចេតនា។

ជាចុងក្រោយ ក្រុមខ្ញុំបាទសូមជូនពរដល់សាស្ត្រាចារ្យ និងមិត្តនិស្សិតគ្រប់រូបឱ្យមានសុខភាពល្អ និងសំណាងល្អ។ សូមអរគុណ ចំពោះការចំណាយពេលវេលាយកចិត្តទុកដាក់លើសារណារបស់ក្រុមខ្ញុំបាទ៕

ថ្ងៃសុក្រ ១៥ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

**ហត្ថលេខា**




**តុប ស្រីភ័ស** **តាំង កាហ្វុង**

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**....................................................................................................១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃការសុំកូន**

**ផ្នែកទី ១ ៖ ទស្សនទានទូទៅនៃសុំកូន**..........................................................................៥

១.១. និយមន័យនៃសុំកូន...........................................................................................៦

១.១.១. គោលបំណងនៃការសុំកូន.............................................................................៦

១.១.២. ទិដ្ឋភាពទូទៅនៃសុំកូន ..................................................................................៦

១.១.៣. លក្ខណៈពិសេសនៃសុំកូន ............................................................................ ៧

១.២. ប្រភេទ និងសារៈសំខាន់នៃសុំកូន ..................................................................... ៧

១.២.១. ប្រភេទនៃសុំកូន.......................................................................................... ៧

១.២.២. សារៈសំខាន់នៃសុំកូន...................................................................................៨

១.៣. វត្តមាននៃរបបសុំកូននៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា....................................................៨

១.៣.១. ប្រព័ន្ធគតិយុត្តកម្ពុជា ....................................................................................៩

១.៣.២. ការវិវត្តនៃដំណើរការគតិយុត្តសុំកូន .................................................................៩

១.៤. យុទ្ធសាស្ត្រដើម្បីការពារចំពោះការសុំ.............................................................. ១១

**ផ្នែកទី ២៖ ការប្រៀបធៀបសុំកូនពេញលេញ សុំកូនធម្មតា និងសារប្រយោជន៍នៃសុំកូន**..១១

២.១. ការប្រៀបធៀបសុំកូនពេញលេញ សុំកូនធម្មតា ................................................. ១១

២.២. សារប្រយោជន៍សុំកូន ......................................................................................១២

២.២.១. ចំពោះសង្គម.................................................................................................១២

២.២.២. ចំពោះបុគ្គល ................................................................................................១៣

**ជំពូកទី ២**

**សុំកូនពេញលេញ**

**ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃសុំកូនពេញលេញ** .........................................................១៤

១.១ គោលបំណងនៃការបង្កើតរបបសុំកូនពេញលេញ...................................................... ១៤

១.១.១. ការពារផលប្រយោជន៍របស់កូនសុំ ..................................................... ១៥
១.១.២. ការផ្តល់នូវគ្រួសារថ្មីដ៏ល្អ ..................................................... ១៥
**ផ្នែកទី២ ៖ លក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញ** ..................................................... ១៥
២.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតស្មុំកូនពេញលេញ ..................................................... ១៦
២.១.១. លក្ខខណ្ឌពាក់ព័ន្ធនឹងឳពុកម្តាយចិញ្ចឹម ..................................................... ១៦
២.១.២. លក្ខខណ្ឌពាក់ព័ន្ធនឹងឳពុកម្តាយបង្កើត ..................................................... ១៨
២.១.៣. លក្ខខណ្ឌពាក់ព័ន្ធនឹងកុមារដែលក្លាយជាកូនសុំ ..................................................... ១៩
**ផ្នែកទី៣ ៖ លក្ខខណ្ឌទម្រង់នៃការបង្កើតស្មុំកូនពេញលេញ** ..................................................... ២០
៣.១. ការវិវត្តនៃសង្គម ..................................................... ២១
៣.២. ស្ថានភាពគ្រួសារ ..................................................... ២១
៣.៣. ការដាក់ពាក្យសុំ ..................................................... ២១
៣.៤. ការពិនិត្យពាក្យសុំ ..................................................... ២២
៣.៥. ស្ថាប័នទទួលពាក្យសុំ ..................................................... ២៣
៣.៦. អំឡុងពេលសាកល្បងចិញ្ចឹម ..................................................... ២៤
៣.៧. អានុភាពនៃស្មុំកូនពេញលេញ ..................................................... ២៥
៣.៧.១. អានុភាពចំពោះកូនសុំ ..................................................... ២៥
៣.៧.២. អានុភាពចំពោះឳពុកម្តាយបង្កើត ..................................................... ២៦
៣.៧.៣. អានុភាពចំពោះឳពុកម្តាយចិញ្ចឹម ..................................................... ២៦
**ផ្នែកទី៤៖ ការកាត់កាល់ស្មុំកូនពេញលេញ** ..................................................... ២៧
៤.១. លក្ខខណ្ឌនៃការកាត់កាល់ ..................................................... ២៧
៤.១.១. តំណាងអយ្យការ ..................................................... ២៧
៤.១.២. ឳពុកម្តាយបង្កើត ..................................................... ២៧
៤.១.៣. កូនសុំ ..................................................... ២៧
៤.២. មូលហេតុនៃការកាត់កាល់ ..................................................... ២៧
៤.៣. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ ..................................................... ២៨
៤.៤. សិទ្ធិរបស់កូនស្មុំពេញលេញ ..................................................... ២៨

៤.៤.១. សិទ្ធិទទួលដឹងពីកំណើត ........ ២៨
៤.៤.២. សិទ្ធិប្រើប្រាស់នាមត្រកូលដែលពេញចិត្ត ........ ២៩
៤.៤.៣. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយ ........ ២៩
៤.៤.៤. សិទ្ធិទទួលបានអាហារកាតព្វកិច្ច ........ ៣០
៤.៤.៥. សិទ្ធិផ្ញើនិងទទួលសន្តតិកម្ម ........ ៣០
៤.៤.៦. សិទ្ធិប្តឹងទាមទារមរតក ........ ៣០

## ជំពូកទី ៣
## សុំកូនធម៌តា

**ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃសុំកូនធម៌តា** ........ ៣២
១.១. និយមន័យ ........ ៣២
១.២. លក្ខណៈពិសេសនៃសុំកូនធម៌តា ........ ៣៣
**ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតសុំកូនធម៌តា** ........ ៣៣
២.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតសុំកូនធម៌តា ........ ៣៣
២.១.១. លក្ខខណ្ឌចំពោះឪពុកម្ដាយចិញ្ចឹម ........ ៣៣
២.១.២. លក្ខខណ្ឌចំពោះកូនសុំធម៌តា ........ ៣៥
**ផ្នែកទី៣ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនធម៌តា** ........ ៣៥
៣.១. លក្ខខណ្ឌគ្រឹះ ........ ៣៥
៣.២. លក្ខខណ្ឌទម្រង់នៃការបង្កើតសុំកូនធម៌តា ........ ៣៦
៣.២.១ .លក្ខខណ្ឌទម្រង់ ........ ៣៦
៣.២.២. ទម្រង់នៃពាក្យសុំ ........ ៣៨
៣.២.៣. ស្ថាប័នទទួលពាក្យសុំ ........ ៣៨
៣.៣. អានុភាពនៃសុំកូនធម៌តាចំពោះបុគ្គលភាព ........ ៣៨
៣.៣.១. អានុភាពចំពោះកូនសុំ ........ ៣៨
៣.៣.២. អានុភាពចំពោះឪពុកម្ដាយបង្កើត ........ ៣៩
៣.៣.៣. អានុភាពចំពោះឪពុកម្ដាយចិញ្ចឹម ........ ៣៩
**ផ្នែកទី៤ ៖ ការកាត់កាល់សុំកូនធម៌តា** ........ ៣៩

៤.១. លក្ខខណ្ឌនៃកាត់កាល់ស្មុំកូនធម្មតា ....................................................................................៣៩
៤.១.១.ការកាត់កាល់ស្មុំកូនធម្មតាតាមការព្រមព្រៀង ............................................................ ៤០
៤.១.២.ការកាត់កាល់ស្មុំកូនធម្មតាតាមពាក្យបណ្តឹងរបស់ភាគីម្ខាង ........................................ ៤១
៤.២. មូលហេតុនៃការកាត់កាល់ស្មុំកូនធម្មតា........................................................................... ៤១
៤.៣. អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា........................................................................... ៤១
៤.៤. សិទ្ធិរបស់កូនស្មុំកូនធម្មតា ..........................................................................................៤២
៤.៤.១. សិទ្ធិប្រើប្រាស់នាមត្រកូលដែលខ្លួនពេញចិត្ត ...........................................................៤២
៤.៤.២. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹម...............៤២
៤.៤.៣. សិទ្ធិទទួលបានអាហារកាតព្វកិច្ច...........................................................................៤២
៤.៤.៤. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម ..................................................................................៤៣
៤.៤.៥. សិទ្ធិប្តឹងទាមទារមរតក .........................................................................................៤៣
**សេចក្តីសន្និដ្ឋាន**................................................................................................................ ៤៤
**អនុសាសន៍**........................................................................................................................ ៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ពីដើមឡើយមនុស្សរស់នៅតែម្នាក់ឯង ឬជាមួយគ្នាបានសុខសាន្តដូចសត្វដែរ ជាសម័យកាលមិនទាន់កកើតមានជារដ្ឋ ជាប្រទេស ជាក្រុម មនុស្សចេះស្រឡាញ់ និងយល់ធុរៈគ្នាទៅវិញទៅមក ហើយបើបានវត្ថុអ្វីមកមិនបានគិតរំលែកទុកសម្រាប់ដល់ថ្ងៃស្អែកឡើយ នៅពេលដែលបានផលប្រយោជន៍មកចេះចែកគ្នាដោយគ្មានការកិបកេងប្រវ័ញ្ចដណ្តើមគ្នា និងមិនបង្កឱ្យមានជម្លោះវិវាទនោះដែរ។

កាលពីដើមមនុស្សរស់នៅក្នុងសភាពធម្មជាតិយូរៗទៅស្រាប់តែមានការប្រែប្រួលពីធម្មជាតិ អាចធ្វើឱ្យគេជួបផលវិបាកក្នុងការរស់នៅ និងចិញ្ចឹមជីវិត គេក៏ចាប់ផ្តើមរកមធ្យោបាយផ្សេងៗកែច្នៃឧបករណ៍នានា និងចេះចិញ្ចឹមសត្វ ដាំដំណាំ ហើយគ្រប់គ្រងឱ្យបានល្អប្រសើរ។ នៅពេលគំនិត របស់មនុស្សមានការវិវត្ត និងកត្តាសេដ្ឋកិច្ចរីកចម្រើនក៏ចាប់ផ្តើមកើតនូវការចង់មានចង់បាន ចង់ល្អតែឯង ឬរស់តែឯង និងដោយសារកត្តានៃការបែងចែកវណ្ណៈ ពណ៌សម្បុរ ក្រុម ឬដោយសារហេតុ ផលនយោបាយ កត្តាជីវភាព សេដ្ឋកិច្ច ច្បាប់ បានធ្វើឱ្យមនុស្សមួយចំនួនមិនចាប់អារម្មណ៍ក្នុងការកសាងគ្រួសារ ពិសេសការរួមរស់នៅជាមួយគ្នាដោយពុំយកកូន ឬដោយសារហេតុផលហ្សែនរបស់គូភាគី។ ក្រោយមកទើបមនុស្សចេះរស់នៅមានការប្រមូលផ្តុំគ្នាជាក្រុម ជាពួក ជាហ្វូង រហូតដល់មានការបង្កើតជារដ្ឋ ជាប្រទេស ហើយមនុស្សចេះរស់នៅតាមបែបកិច្ចសន្យាសង្គម ដែលជាហេតុធ្វើឱ្យគ្រួសារ ឬមនុស្សមួយចំនួនចេះស្រឡាញ់ និងចង់មានកូនរស់នៅជាមួយពួកគេ ហើយជារឿយៗ គេតែងតែសង្កេតឃើញថាគ្រួសារដែលគ្មានកូនមួយចំនួន រមែងសុំកូនពីអ្នកដទៃមកធ្វើជាកូនរបស់ខ្លួនតាមទម្រង់ផ្សេងៗគ្នា ដោយខ្លះតាមបែបប្រពៃណីទំនៀមទំលាប់ ខ្លះតាមច្បាប់ ឬទម្រង់បទដ្ឋានមួយចំនួនទៀត ដោយហេតុនេះហើយទើបក្រុមខ្ញុំបាទលើកយកប្រធានបទស្តីពី « **ការអនុវត្តសុំកូនក្រោមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា** » មកធ្វើការសិក្សាស្រាវជ្រាវជាសារណាបញ្ចប់ការសិក្សា។

សុំកូន ជាយន្តការដែលពាក់ព័ន្ធនឹងកុមារដែលត្រូវការនូវកិច្ចការពារពិសេស ពីព្រោះវាបានលើកកម្ពស់សុខមាលភាពកុមារនៅកម្ពុជា ហេតុដូច្នេះបានជាកម្ពុជាមានបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិជាច្រើន សម្រាប់គ្រប់គ្រងលើវិស័យនេះ។ សុំកូនមានចំណុចសំខាន់ៗដូចជា លក្ខខណ្ឌនៃការបង្កើតដែលឈានទៅរកអានុភាពនៃការសុំ ហើយវាក៏អាចឈានទៅរកការបញ្ចប់ផងដែរនៅពេលមានការកាត់កាល់នោះ។ ទោះបីជាយ៉ាងណាក្តី សុំកូនធ្វើឡើងដើម្បីជាគោលការណ៍មនុស្សធម៌សុទ្ធសាធ។

តើសុំកូនមានគោលបំណង និងសារសំខាន់យ៉ាងដូចម្តេចខ្លះទៅលើកុមារ ដែលត្រូវការកុមារជាទំពាំងស្នងឬស្សីដែលក៏ត្រូវមាននូវកិច្ចការពារពិសេសនោះ? តើវិស័យសុំកូនមានតាំងពីពេលណាមក ហើយរយៈពេលកន្លងមកមានច្បាប់ណាខ្លះអនុវត្តទៅវិស័យសុំកូននេះ? តើការសុំកូន មានពាក់ព័ន្ធនឹងក្រសួងឬស្ថាប័នណាខ្លះ?

ស្មុំកូនមានគោលបំណងក្នុងការធានាបាននូវឧត្តមប្រយោជន៍ និងការការពារសិទ្ធិជាមូលដ្ឋានរបស់ក្មេង ដូចជា កុមារដែលមានឪពុកម្តាយក្រីក្រ ជាពិសេសកុមារដែលត្រូវការកិច្ចការពារពិសេស ដើម្បីឱ្យពួកគេបានរស់នៅមជ្ឈដ្ឋានសមស្រប ឬការអភិវឌ្ឍពេញលេញក្នុងបរិយាកាសគ្រួសារថ្មីប្រកបដោយសុវត្ថិភាព សុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់។ ជាពិសេស គឺការទទួលបានការអប់រំដោយផ្សាភ្ជាប់នូវការយកចិត្តទុកដាក់ពីសំណាក់ស្ថាប័នជាតិ អន្តរជាតិ និងរួមទាំង អង្គការនានា ជាហេតុជំរុញឱ្យកុមារកំព្រាបានរស់នៅក្នុងមជ្ឈដ្ឋានគ្រួសារថ្មីដែលពោរពេញដោយការអាណិត និងទទួលបានអនាគតភ្លឺស្វាងដូចកុមារដទៃទៀតដែរ។ បន្ថែមពីលើនេះ គឺដើម្បីការពារឱ្យរួចផុតពីការរំលោភបំពានផ្សេងៗ ពិសេសឱ្យជៀសផុតពីការជួញដូរ ការកេងប្រវ័ញ្ចកម្លាំងពលកម្មជាដើម។

សារណាមួយនេះ នឹងក្លាយជាឯកសារដ៏មានសារសំខាន់មួយចំពោះវិស័យស្មុំកូននៅកម្ពុជា ពីព្រោះនីតិវិធីនៃដំណើរការស្មុំកូន អាចប្រព្រឹត្តទៅបានលុះត្រាតែរាល់អ្នកដែលជាប់ពាក់ព័ន្ធ និងអាជ្ញាធរដែលមានសមត្ថកិច្ចតម្រូវឱ្យមានចំណេះដឹងគ្រាប់គ្រាន់តាមរយៈការសិក្សាស្វែងយល់។ អាស្រ័យហេតុនេះ បានជារាល់លិខិតបទដ្ឋានដែលទាក់ទងនឹងវិស័យស្មុំកូន ក៏ដូចជា សារណានេះផ្ទាល់ គឺជាកាតាលីករជំរុញឱ្យអ្នកដែលចង់ស្វែងយល់ទទួលបាននូវចំណេះដឹងនេះយ៉ាងទូលំទូលាយ។

និយាយជារួម អត្ថបទនេះពិតជាពន្លឺប្រទីបក្នុងការបង្ហាញផ្លូវដល់រាល់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធបានយល់ច្បាស់អំពីនីតិវិធីទាំងអស់ ដោយសារវាក៏បានបំភ្លឺរាល់ចម្ងល់ដល់បុគ្គលដែលមានបំណងស្មុំកូនផងដែរ។ ដើម្បីជាការដោះស្រាយគ្រប់រាល់ចំណោទអំពីបញ្ហាស្មុំកូននៃប្រធានបទខាងលើនេះ ក្រុមខ្ញុំបាទបានបែងចែកការសិក្សានេះជា ៣ ជំពូករួមមាន៖

- **ជំពូកទី១ អំពីសញ្ញាណទូទៅនៃការស្មុំកូន**

ផ្នែកទី១៖ ទស្សនទានទូទៅនៃស្មុំកូន

១.១.និយមន័យនៃស្មុំកូន

១.២.ប្រភេទ និងសារៈសំខាន់នៃស្មុំកូន

១.៣.វត្តមាននៃរបបស្មុំកូននៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា

១.៤.យុទ្ធសាស្ត្រដើម្បីការពារចំពោះការសុំ

ផ្នែកទី២៖ ការប្រៀបធៀបស្មុំកូនពេញលេញ ស្មុំកូនធម្មតា និង សារប្រយោជន៍នៃស្មុំកូន

២.១. ការប្រៀបធៀបស្មុំកូនពេញលេញ ស្មុំកូនធម្មតា

២.២.សារប្រយោជន៍ស្មុំកូន

- **ជំពូកទី២ ស្មុំកូនពេញលេញ**

ផ្នែកទី១៖ សញ្ញាណទូទៅនៃស្មុំកូនពេញលេញ

១.១.គោលបំណងនៃការបង្កើតរបបស្មុំកូនពេញលេញ

ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញ

២.១.លក្ខគ្រឹះនៃការបង្កើតស្មុំកូនពេញលេញ

ផ្នែកទី៣៖ លក្ខខណ្ឌទម្រង់នៃការបង្កើតស្មុំកូនពេញលេញ

៣.១.ការវិវត្តនៃសង្គម

៣.២.ស្ថានភាពគ្រួសារ

៣.៣.ការដាក់ពាក្យសុំ

៣.៤.ការពិនិត្យពាក្យសុំ

៣.៥.ស្ថាប័នទទួលពាក្យសុំ

៣.៦.អំឡុងពេលសាកល្បងចិញ្ចឹម

៣.៧.អានុភាពនៃស្មុំកូនពេញលេញ

ផ្នែកទី៤៖ ការកាត់កាល់ស្មុំកូនពេញលេញ

៤.១.លក្ខខណ្ឌនៃការកាត់កាល់

៤.២.មូលហេតុនៃការកាត់កាល់

៤.៣.អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ

៤.៤.សិទ្ធិរបស់កូនស្មុំពេញលេញ

- **ជំពូកទី ៣ ស្មុំកូនធម្មតា**

ផ្នែកទី១៖ សញ្ញាណទូទៅនៃស្មុំកូនធម្មតា

១.១.និយមន័យ

១.២.លក្ខណៈពិសេសនៃស្មុំកូនធម្មតា

ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា

២.១.លក្ខខណ្ឌគ្រឹះនៃការបង្កើតស្មុំកូនធម្មតា

ផ្នែកទី៣៖ លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា

៣.១.លក្ខខណ្ឌគ្រឹះ

៣.២.លក្ខខណ្ឌទម្រង់នៃការបង្កើតស្មុំកូនធម្មតា

៣.៣.អានុភាពនៃស្មុំកូនធម្មតាចំពោះបុគ្គភាព

ផ្នែកទី៤៖ ការកាត់កាល់ស្មុំកូនធម្មតា

៤.១.លក្ខខណ្ឌនៃកាត់កាល់ស្មុំកូនធម្មតា

៤.២.មូលហេតុនៃការកាត់ស្មុំកូនធម្មតា

៤.៣.អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា

៤.៤.សិទ្ធិរបស់កូនស្មុំកូនធម្មតា

# ជំពូកទី ១
# សញ្ញាណទូទៅនៃការសុំកូន

# ជំពូកទី ១

# សញ្ញាណទូទៅនៃការសុំកូន

ឪពុកម្តាយ មានកាតព្វកិច្ចបីបាច់ថែរក្សាកូនរបស់ខ្លួនប្រកបដោយជីវភាពគ្រប់គ្រាន់ ដើម្បីធានាបាននូវសុខភាព និងសុខមាលភាពរបស់កូនដែលជាវ័យកុមារ ព្រោះកុមារជាវ័យទន់ខ្សោយ ពុំមានភាពចាស់ទុំទាំងផ្នែករាងកាយ និងសតិបញ្ញា។ ចំណែកឯកុមារកំព្រាដែលពុំមានឪពុកម្តាយ ក៏មានសិទ្ធិទទួលបាននូវជំនួយ ការយកចិត្តទុកដាក់ និងការសង្គ្រោះ ហើយត្រូវបានការពារ និងថែរក្សាថែទាំ ពិសេសដោយច្បាប់របស់ប្រទេស ក៏ដូចជាគោលការណ៍នានារបស់សង្គមជាតិទាំងមូល។

ក្រៅពីទំនាក់ទំនងបុត្តភាពតាមបែបធម្មជាតិ ក្រមរដ្ឋប្បវេណីក៏ទទួលស្គាល់ការបង្កើតឱ្យមានទំនាក់ទំនងបុត្តភាពតាមរយៈសុំកូន ហើយការបង្កើតឱ្យមានប្រព័ន្ធសុំកូននេះដែរ គឺដើម្បីបង្កើតសន្តតិជននៃទ្រព្យសម្បត្តិរបស់គ្រួសាររបស់ឪពុកម្តាយចិញ្ចឹម បង្កើតឱ្យមានកម្លាំងការពារមើលថែរក្សា និងគិតគូរដល់ផលប្រយោជន៍របស់កុមារដែលពុំមានស្ថានភាពនៃការថែរក្សាដោយសមរម្យពីឪពុកម្តាយបង្កើត។

ដើម្បីឱ្យការអនុវត្តការសុំកូនមានប្រសិទ្ធភាព និងភាពសុក្រឹត្យ គឺត្រូវតែអនុវត្តទៅតាមគោលការណ៍នៃបទប្បញ្ញត្តិ ដោយគោរពបែបបទ លក្ខខណ្ឌ នីតិវិធី និងអានុភាពឱ្យបានត្រឹមត្រូវ។

## ផ្នែកទី ១ ៖ ទស្សនទានទូទៅនៃសុំកូន

គោលគំនិតនៃការតាក់តែងប្បញ្ញត្តិស្តីពីការសុំកូន មានហេតុផលជាច្រើន ដូចជាដើម្បីបន្តវង្សត្រកូលជាដើម។ ប៉ុន្តែចុងក្រោយ គឺដើម្បីផលប្រយោជន៍របស់កូនសុំ មានន័យថា ចង់ឱ្យកូនសុំទទួលបាននូវគ្រួសារថ្មី ដែលល្អជាងគ្រួសារពីមុន។ ការទទួលស្គាល់ប្រព័ន្ធនេះ គឺមានប្រយោជន៍ដល់កុមារដែលក្រីក្រ ឬកំព្រាមានឱកាសទទួលបានគ្រួសារថ្មីដែលអាចជួយឱ្យជីវិតរបស់ពួកគេបានប្រសើរឡើង។ ហើយហេតុផលដែលគេបង្កើតឱ្យមានរបបសុំកូនឡើង គឺមានគោលបំណងបន្តពូជពង្សវង្សត្រកូល សំដៅទៅលើអ្នកគ្មានកូន ឬអ្នកដែលអសមត្ថភាពក្នុងការឱ្យកំណើតកូនដោយខ្លួនឯង ប៉ុន្តែមូលហេតុនេះ មិនត្រូវបានបញ្ញត្តិនៅក្នុងច្បាប់ទេ ពីព្រោះច្បាប់កំណត់តែមូលហេតុផលប្រយោជន៍កុមារប៉ុណ្ណោះ ហេតុនេះ ពេលតុលាការធ្វើការសម្រេច តុលាការនឹងពិចារណាដោយផ្អែកលើផលប្រយោជន៍របស់ក្មេង។

**ឧទាហរណ៍៖** បុគ្គលម្នាក់ គាត់មានកូន ៣នាក់រួចហើយ បន្ទាប់មក គាត់ចង់សុំកូនគេទៅចិញ្ចឹមទៀត ចំណុចនេះ ច្បាប់មិនមានបញ្ញត្តិហាមឃាត់ទេ ក៏ប៉ុន្តែផ្តល់សិទ្ធិឱ្យតុលាការជាអ្នកសម្រេច តើគួរឱ្យគាត់បង្កើតសុំកូនដែរឬទេ? បើគាត់មានកូនច្រើនហើយ បើតុលាការយល់ឃើញថាស្ថានភាពគ្រួសាររបស់គាត់មិនសូវមានជីវភាពធូរធាទេ តែគាត់នៅតែចង់សុំកូនយកទៅចិញ្ចឹម ដើម្បីធ្វើជាអ្នកបម្រើក៏ថាបាន តែបើពិនិត្យទៅគ្រួសារនោះមានជីវភាពធូរធា មានទ្រព្យសម្បត្តិសមល្មមនឹងមើលថែទាំកូនសុំនោះបាន តុលាការអាចអនុញ្ញាតឱ្យចិញ្ចឹម នេះ

វាគ្រាន់តែជាផ្នែកមួយនៃការពិចារណាទេ ធាតុពិតគឺអាស្រ័យលើស្ថានភាពជាក់ស្តែង។ រីឯចំពោះអ្នកមិនមានកូនសោះ តុលាការមានភាពជឿជាក់ច្រើនថា អ្នកនោះនឹងសុំក្នុងគោលបំណងធ្វើជាកូនពិតប្រាកដមែន។

### ១.១. និយមន័យនៃស្មុំកូន

ស្មុំកូន (Eng. Adopt, Fr. Adopt) គឺជាកិច្ចសន្យាយ៉ាងឱឡារិកដែលធ្វើដោយបុគ្គលពីរនាក់ គឺឪពុក ឬម្តាយ និងកូនចិញ្ចឹមមានទំនាក់ទំនងដូចគ្នានឹងឪពុកម្តាយជាមួយកូនបង្កើត[1]។

ស្មុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នាដូចជាបុត្តភាពមានខាន់ស្លា។

#### ១.១.១ គោលបំណងនៃការស្មុំកូន

វត្ថុបំណងនៃស្មុំកូន គឺផ្តោតសំខាន់ចម្បងទៅលើគោលការណ៍មនុស្សធម៌សុទ្ធសាធ ដោយផ្សាភ្ជាប់នូវការយកចិត្តទុកដាក់ចំពោះកុមារ ដើម្បីផ្តល់នូវការការពារកុមារឱ្យរួចផុតពីការរំលោភបំពានផ្សេងៗ ផ្តល់នូវការចិញ្ចឹមបីបាច់ថែរក្សា ផ្តល់សេវាសុខភាព ការអប់រំរៀនសូត្រ ជាពិសេសការគិតគូទៅលើការគោរពសិទ្ធិជាមូលដ្ឋានរបស់កុមារ សិទ្ធិទទួលបានការការពារ សិទ្ធិទទួលបានការអប់រំរៀនសូត្រ ការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម ដើម្បីឧត្តមប្រយោជន៍កុមារនាពេលអនាគត។

#### ១.១.២. ទិដ្ឋភាពទូទៅនៃស្មុំកូន

ដោយសារការចង់ជួយសង្គ្រោះ ការអាណិតដល់កុមារដែលមានឪពុកម្តាយក្រីក្រ ឬកុមារកំព្រា ទើបធ្វើឱ្យពលរដ្ឋខ្លះដែលគ្មានកូន សុំកុមារទាំងនោះយកមកធ្វើជាកូនចិញ្ចឹម។ មានកុមារមិនតិចទេដែលមានសំណាងដោយការសុំនេះ ពួកគេបានរស់នៅក្នុងគ្រួសារអ្នកមានស្តុកស្តម្ភ និងទទួលបាននូវការថ្នាក់ថ្នមបីបាច់យ៉ាងកក់ក្តៅ។ ផ្ទុយមកវិញ ក៏មានកុមារមួយចំនួនតូចដែរដែលគ្មានសំណាងនោះ ហើយត្រូវបានគេវាយដំធ្វើបាបប្រំធាក់ធ្វើអាជីវកម្មលើកម្លាំងពលកម្ម ឬយកទៅជួញដូរជាដើម។ ដើម្បីជៀសវាងរាល់ការជួញដូរទាំងឡាយទៅលើកុមារ និងសម្រាប់តម្រង់ទិសទៅដល់ផ្នែកពាក់ព័ន្ធ ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យនេះ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិអំពីស្មុំកូន ដែលមានសរុបចំនួន ២៧មាត្រា គឺចាប់ពីមាត្រា១០០៧ ដល់មាត្រា១០៣៣[2]។ ក្នុងនោះ មាត្រា ១០០៧ បានផ្តល់អំណាចពេញលេញដល់តុលាការក្នុងការពិចារណា និងសម្រេចឱ្យមានការស្មុំកូន[3]។ ដូចគ្នាផងដែរ នៅប្រទេសដទៃទៀត ដូចជា នៅអឺរ៉ុប បានកំណត់ថាការស្មុំកូនពេញលេញមានសុពលភាព លុះត្រាតែមានការសម្រេចរបស់តុលាការ ឬអាជ្ញាធររដ្ឋបាល។ អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រង់មាត្រា២១ ក៏បានទាមទារឱ្យមានការពិចារណាជាអតិបរមាទៅលើផលប្រយោជន៍របស់កុមារដែល

---

[1] *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧)។

[2] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៧ ដល់ ១០៣៣។

[3] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៧។

ធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចដែរ[4]។ ដោយឡែក ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩ បានបញ្ញត្តិចំនួន ១០ជំពូក និង៥៨មាត្រា លើករណីស្រដៀងគ្នាក្នុងវិស័យនេះដែរ[5]។

ការតាក់តែងច្បាប់នេះឡើង គឺត្រូវបានអនុវត្តអនុលោមទៅតាមកម្មវិធីនយោបាយជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី២ សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ដែលចែងជាអាទិ៍ថា « **រាជរដ្ឋាភិបាលប្តូរផ្តាច់ដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីទប់ស្កាត់អំពើគាបសង្កត់ អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ ការពង្រឹងអនុវត្តច្បាប់ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌** »។

#### ១.១.៣. លក្ខណៈពិសេសនៃស្មុំកូន

យោងតាមក្រមរដ្ឋប្បវេណី ស្មុំកូនក្នុងប្រទេសអាចជាស្មុំកូនពេញលេញ និងស្មុំកូនធម្មតា។ ដោយឡែករាល់ជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ហើយមានបំណងសុំកុមារកម្ពុជាយកទៅចិញ្ចឹម នៅក្នុងប្រទេសដែលខ្លួនមានលំនៅអចិន្ត្រៃយ៍ក្រៅពីប្រទេសកម្ពុជា ត្រូវអនុវត្តទៅតាមច្បាប់ស្មុំកូនអន្តរប្រទេស[6]។

ចំពោះលក្ខណៈពិសេសនៃស្មុំកូន គឺតម្រូវឱ្យបំពេញនូវលក្ខខណ្ឌមួយចំនួន ដូចជា (១) **ការបង្កើត** ដោយពាក់ព័ន្ធទៅលើលក្ខខណ្ឌចំពោះឪពុកម្តាយទៅលើកូនសុំ បន្ទាប់មក គឺ (២) **អានុភាពទៅលើការសុំ** ជាចុងក្រោយគឺ (៣) **ការកាត់កាល់។** ចំណែកឯស្មុំកូនអន្តរប្រទេស ក៏មិនខុសពីស្មុំកូនក្នុងប្រទេសប៉ុន្មានដែរ ដោយសារស្មុំកូនអន្តរប្រទេសធ្វើក្នុងទម្រង់ស្មុំកូនពេញលេញ។ ម្យ៉ាងទៀត ស្មុំកូនអន្តរប្រទេសទាមទារឱ្យមាននីតិវិធីច្បាស់លាស់ត្រឹមត្រូវបំផុតចំពោះដំណើរការនៃការស្មុំនេះ ព្រោះមានអាជ្ញាធរដែលមានសមត្ថកិច្ចទាំងក្នុង និងក្រៅប្រទេសនៅអនុវត្តកិច្ចដំណើរការស្មុំកូនប្រភេទនេះ។

### ១.២ ប្រភេទ និងសារៈសំខាន់នៃស្មុំកូន

#### ១.២.១. ប្រភេទនៃស្មុំកូន

ស្មុំកូនត្រូវបានបែងចែកជាពីរ គឺស្មុំកូនពេញលេញ និងស្មុំកូនធម្មតា។ ស្មុំកូនទាំងពីរប្រភេទនេះ មានលក្ខខណ្ឌ និងអានុភាពខុសគ្នា ដោយក្នុងនោះ ស្មុំកូនពេញលេញមានលក្ខខណ្ឌក្នុងការបង្កើតតឹងរឹងជាងស្មុំកូនធម្មតា ដូចជាករណីស្មុំកូនពេញលេញអាចបង្កើតបានចំពោះតែកុមារតូចៗដែលជាគោលការណ៍មានអាយុតិចជាង ៨ឆ្នាំ និងអាចបង្កើតបានចំពោះតែបុគ្គល ដែលមានសហព័ទ្ធប៉ុណ្ណោះ ហេតុនេះបុគ្គលដែលមិនទាន់មានសហព័ទ្ធមិនអាចបង្កើតស្មុំកូនពេញលេញបានទេ តែអាចបង្កើតស្មុំកូនធម្មតាបាន។ ម្យ៉ាងវិញទៀត ចំណុចដែលខុសគ្នាទាំងស្រុងគឺ ស្មុំកូនពេញលេញមានអានុភាពបង្កើតនូវញាតិថ្មី (ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយ

[4] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា១០០៧។

[5] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, លេខ នស/រកម/១២០៩/០២៤, ៣០ ធ្នូ ២០០៩។

[6] ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ, លេខ ២២៨០ ស.អ.យ, ១១ តុលា ២០១១។

ចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកចិញ្ចឹម) ឱ្យកូនសុំ ដោយកាត់ផ្តាច់ទាំងស្រុងនូវទំនាក់ទំនងញាតិ រវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត។

ដោយឡែក សុំកូនធម្មតាមានអានុភាពបង្កើតនូវញាតិថ្មី ដោយមិនផ្តាច់នូវទំនាក់ទំនងញាតិជាមួយនឹងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតទេ ពោលគឺញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតនៅតែបន្ត[7]។

### ១.២.២. សារៈសំខាន់នៃសុំកូន

សារសំខាន់នៃសុំកូនពេញលេញ កូនសុំពេញលេញបានបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាមួយឪពុកម្តាយចិញ្ចឹម គឺកូនសុំមានឋានៈ និងសិទ្ធិដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម។ កូនសុំអាចគេចផុតពីភាពរស់នៅដោយជីវភាពក្រីក្រជាមួយឪពុកម្តាយបង្កើត ហើយដោយជំនួសមកវិញនូវមជ្ឈដ្ឋានថ្មី ដែលមានឪពុកម្តាយចិញ្ចឹមផ្តល់ឱ្យនូវអនាគតភ្លឺស្វាង។ ជាពិសេសសុំកូនពេញលេញមានការសម្រេចដោយតុលាការដែលច្បាប់ទទួលស្គាល់។

សារសំខាន់នៃសុំកូនធម្មតា កូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។ មួយវិញទៀត កូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមក។ មានន័យថា ចំណងទំនាក់ទំនងរវាងកូនសុំ និងឪពុកម្តាយបង្កើតមិនត្រូវបានកាត់ផ្តាច់ឡើយ។ ម្យ៉ាងទៀត អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនក៏បាន។ ក្រោយពីបញ្ចប់នីតិវិធីសុំកូនធម្មតា កូនសុំបានរស់នៅក្នុងគ្រួសារសមរម្យ និងមានអធ្យាស្រ័យល្អពីឪពុកម្តាយ ពិសេសបានសិក្សារៀនសូត្រ ការថែទាំសុខភាពជាអចិន្ត្រៃយ៍។ ជាចុងក្រោយ ប្រព័ន្ធសុំកូនធម្មតាត្រូវបានបង្កើតឡើង ដោយតម្រូវឱ្យមានការពាក់ព័ន្ធពីតុលាការ ដើម្បីបង្កើតអានុភាពញាតិលោហិតតាមផ្លូវច្បាប់ដូចជាសន្តតិកម្ម និងអាហារកិច្ចជាដើម[8]។

## ១.៣. វត្តមាននៃរបបសុំកូននៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា

សុំកូនត្រូវបានបញ្ញត្តិចាប់ពីមាត្រា១០៨ ដល់មាត្រា១២២ នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ប៉ុន្តែរបបសុំកូនតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារខុសគ្នាអំពីសុំកូនតាមក្រមរដ្ឋប្បវេណី ដោយសុំកូនតាមច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារបង្កើតឡើងត្រឹមតែកិច្ចសន្យា រវាងភាគីតែប៉ុណ្ណោះ ពោលគឺសុំកូនមិនត្រូវបានបង្កើតឡើងតាមផ្លូវតុលាការនោះទេ[9]។ ម៉្យាងទៀត សុំកូនត្រូវបានកម្រិតចំនួនកូន គឺជាគោលការណ៍មិនឱ្យលើសពី ២(ពីរ)នាក់។

[7] ទេព បូផល, សិក្ខាសាលាស្តីពីបុគ្គភាព និងអំណាចមេបា (បទបង្ហាញស្តីពីសុំកូន), ៣០ ឧសភា ២០១៥។

[8] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៦។

[9] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា១០៨ ដល់ ១២២។

ចំណែកឯក្រមរដ្ឋប្បវេណី ដើម្បីសុំកូនតាមផ្លូវច្បាប់បាន លុះត្រាតែធ្វើតាមផ្លូវតុលាការ បើពុំដូច្នោះទេ សុំកូនមិនបង្កើតអានុភាពឡើយ ហើយពុំមានកម្រិត អំពីចំនួនកូនសុំទេ ប៉ុន្តែការសម្រេចបង្កើតសុំកូនត្រូវវិនិច្ឆ័យដោយផ្តោតលើផលប្រយោជន៍របស់កុមារ។

**១.៣.១. ប្រព័ន្ធគតិយុត្តកម្ពុជា**

ក្នុងវិស័យសុំកូនកម្ពុជា ដំបូងឡើយ គឺបានអនុវត្តយកតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ប៉ុន្តែបច្ចុប្បន្នយកតាមក្រមរដ្ឋប្បវេណី ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ វិញ ដែលបញ្ញត្តិកថាខណ្ឌទី១ អំពីសុំកូនពេញលេញ ( ចាប់ពីមាត្រា១០០៧ ដល់មាត្រា១០១៩ ) និងកថាខណ្ឌទី២ (ចាប់ពីមាត្រា១០២០ ដល់មាត្រា១០៤២)[10]។ ដោយឡែក ក្របខណ្ឌច្បាប់ដែលគ្រប់គ្រងការសុំកូនយកទៅចិញ្ចឹមនៅបរទេសវិញ ដំបូងឡើយ គឺមានអនុក្រឹត្យឆ្នាំ២០០១ ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាទៅចិញ្ចឹមនៅបរទេស។ ក្រោយមក នៅឆ្នាំ២០០៧ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ( អនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៩៣ ) ហើយនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ រដ្ឋសភាកម្ពុជាក៏បានអនុម័តច្បាប់មួយទៀត គឺ « ច្បាប់ស្តីពីសុំកូនអន្តរប្រទេស » ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ និងអនុលោមទៅតាមអនុសញ្ញាស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនោះ។

**១.៣.២. ការវិវត្តនៃដំណើរការគតិយុត្តសុំកូន**

ការងារសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺមានចាប់តាំងពីឆ្នាំ១៩៨៧ ដោយមុនដំបូង គឺចាប់ផ្តើមអនុវត្តការផ្តល់កូនសុំជូនដល់បុគ្គលិកបរទេសរបស់អង្គការអន្តរជាតិ និងអង្គការក្រៅរាជរដ្ឋាភិបាល ដែលមកបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជា ហើយបន្ទាប់មកបានអនុវត្តចំពោះប្រជាពលរដ្ឋបរទេស ដែលបានមកទំនាក់ទំនងសុំកូនពីកម្ពុជា។

បន្ទាប់ពីច្បាប់ស្តីពីសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តឱ្យប្រើប្រាស់កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ កន្លងមក ដំណើរការសុំកូនអន្តរប្រទេសនៅកម្ពុជា នៅមិនទាន់អាចបើកឱ្យដំណើរការឡើងវិញស្របទៅតាមច្បាប់នេះនៅឡើយទេ។ ដោយហេតុថាកម្ពុជាត្រូវការពេលវេលាឱ្យបានគ្រប់គ្រាន់ សម្រាប់រៀបចំកសាងលិខិតបទដ្ឋានគតិយុត្តនានា សំដៅជំរុញការអភិវឌ្ឍច្បាប់ឱ្យបានល្អប្រសើរស្របតាមអនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ ជាមួយគ្នានេះដែរ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតនូវរដ្ឋបាលសុំកូនអន្តរប្រទេស ដែលជាសេនាធិការរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីគ្រប់គ្រងចាត់ចែង និងតាមដានត្រួតពិនិត្យលើការងារសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាថាការងារសុំកូនអន្តរប្រទេស ប្រព្រឹត្តទៅស្របតាមគោលបំណង នៃគោល

[10] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៧ ដល់ ១០១៩ និង កថាខណ្ឌទី២ មាត្រា ១០២០ ដល់ ១០៤២។

នយោបាយការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់កុមារក៏តម្រូវឱ្យអនុលោមតាមលិខិតបទដ្ឋានជាតិ និងអន្តរជាតិដែលបានកំណត់។ ដំណើការស្មុំកូនអន្តរប្រទេស ត្រូវបានផ្អាកទៅវិញនៅឆ្នាំ២០១១ បន្ទាប់ពីឃើញថា កុមារកម្ពុជាមួយចំនួនត្រូវរងគ្រោះ និងមានករណីជួញដូរកុមារមួយចំនួនស្ថិតក្រោមស្លាកស្មុំកូនអន្តរប្រទេសនេះ។ ការផ្អាកជាបណ្ដោះអាសន្នរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺដើម្បីផ្តល់ឱកាសឱ្យអាជ្ញាធរកម្ពុជានូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនធានា និងការពារដល់ឧត្តមប្រយោជន៍របស់កុមារ។

រដ្ឋបាលស្មុំកូនអន្តរប្រទេសដូចជាអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសដែលស្ថិតក្រោមចំណុះឱ្យ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានជម្រាបជូននូវលទ្ធផលសំខាន់ៗដូចជាៈ

| ល.រ. | ឈ្មោះបទដ្ឋានគតិយុត្ត |
|---|---|
| ១ | ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា |
| ២ | ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលស្មុំកូនអន្តរប្រទេស |
| ៣ | ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៤ | ប្រកាសរួមស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់ស្មុំកូនអន្តរប្រទេស |
| ៥ | ប្រកាសរួម ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦ | ប្រកាសស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេស និងសេចក្តីណែនាំស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសដើម្បីធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅកម្ពុជា |
| ៧ | ប្រកាសស្តីពីការណែនាំអនុវត្តនីតិវិធីស្មុំកូនអន្តរប្រទេសដោយសាច់ញាតិ |
| ៨ | ប្រកាសស្តីពីការណែនាំអនុវត្តនីតិវិធីស្មុំកូនអន្តរប្រទេស ចំពោះកុមារដែលត្រូវបានថែទាំពិសេស និងកុមារមានតម្រូវការពិសេស |
| ៩ | ប្រកាសស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌ |
| ១០ | ប្រកាសស្តីពីការប្រើប្រាស់អក្សរកាត់ រូបសញ្ញា និងគំរូក្បាលលិខិតរបស់អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស |

| | |
|---|---|
| ១១ | សៀវភៅណែនាំស្តីពីនីតិវិធីពិនិត្យសំណុំឯកសារសុំកូនអន្តរប្រទេស[11]។ |

លើសពីនេះទៀត រដ្ឋបាលសុំកូនអន្តរប្រទេសបានសហការយ៉ាងជិតស្និទ្ធ ជាមួយអង្គការយូនីសេហ្វ និងអ្នកជំនាញការផ្នែកច្បាប់នៃការិយាល័យអចិន្ត្រៃយ៍អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេសក្នុងការរៀបចំកសាងលិខិតបទដ្ឋាន បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីជំនាញ ដើម្បីពង្រឹងសមត្ថភាព និងបង្កើននូវបទពិសោធន៍ថ្មីៗបន្ថែមទៀត ពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេស។

### ១.៤. យុទ្ធសាស្ត្រដើម្បីការពារចំពោះការសុំ

ក្នុងយុទ្ធសាស្ត្រ នេះជាវិធានការមួយដើម្បីឱ្យកាន់តែល្អប្រសើរដល់កុមារដោយទាំងអង្គការ ក៏ដូចជាក្រសួងទទួលបន្ទុករួមទាំងរដ្ឋាភិបាលបានរួមដៃគ្នារិះរកផែនការទប់ស្កាត់ហេតុការណ៍ផ្សេងៗ ចំពោះជនទុច្ចរិតដែលមានបំណងយកការសុំកូនអន្តរប្រទេសធ្វើជាជំនួញក្នុងការរកស៊ីដើម្បីជាប្រយោជន៍ផ្ទាល់របស់ពួកគេ។

ដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាពដល់កុមារឱ្យរួចពីការកេងប្រវ័ញ្ចគ្រប់រូបភាព ដោយគិតតែប្រយោជន៍ផ្ទាល់ខ្លួន ហេតុនេះហើយបានជាច្បាប់ស្តីពីសុំកូនអន្តរប្រទេសបានកំណត់នូវយន្តការការពារចំពោះកូនសុំ ដើម្បីធានាថាកុមារជាកូនសុំនោះទទួលបាននូវកិច្ចគាំពារ និងជំនួយឧបត្ថម្ភដ៏សមស្របពីឪពុកម្តាយ ចិញ្ចឹមដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងឯកសារអន្តរជាតិនានាផ្សេងទៀត ស្តីពីសិទ្ធិកុមារ និងមនុស្សធម៌។ ដើម្បីជាយន្តការក្នុងការទប់ស្កាត់ចំពោះការសុំត្រូវធានាថាកុមារដែលជាកូនសុំត្រូវមាន សិទ្ធិ ទទួលបាននូវការការពារ សិទ្ធិការពារពីការរំលោភបំពាន។ ពិសេសពួកគេត្រូវទទួលបានសិទ្ធិការពារ ពីការជិះជាន់ កិច្ចគាំពារផ្នែកសេដ្ឋកិច្ច ការថែទាំផ្នែកសុខភាព ការអប់រំជាដើម។ រដ្ឋក៏ត្រូវទប់ស្កាត់នូវការជិះជាន់លើផ្លូវភេទ ការពង្រាត់ ការលក់ដូរ និងការជួញដូរកុមារគ្រប់រូបភាព។

## ផ្នែកទី ២៖ ការប្រៀបធៀបសុំកូនពេញលេញ សុំកូនធម្មតា និងសារប្រយោជន៍នៃសុំកូន

### ២.១. ការប្រៀបធៀបសុំកូនពេញលេញ សុំកូនធម្មតា

ជារូបភាពខុសប្លែកគ្នារវាងសុំកូនទាំងពីរប្រភេទមានដូចតទៅ៖

- **សុំកូនធម្មតា៖**

| | សុំកូនធម្មតា |
|---|---|
| ក | កូនសុំត្រូវមានអាយុតិចជាង៨ឆ្នាំ ជាគោលការណ៍។ |
| ខ | តុលាការអាចបង្កើតសុំកូនបានលុះត្រាតែមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬពីអ្នកអាណាព្យាបាលលើកលែងតែនៅក្នុងករណីពិសេស។ |
| គ | ផ្តាច់ចំណងញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត និងញាតិលោហិតរបស់ឪពុកម្តាយបង្កើត។ |

[11] សិក្ខាសាលាស្តីពីការផ្សព្វផ្សាយលិខិតបទដ្ឋាននានារបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស, ២៦ កុម្ភៈ២០១៤។

| | |
|---|---|
| ឃ | ការកាត់កាល់មានតែមួយប្រភេទ។ |
| ង | តុលាការសម្រេចពីការកាត់កាល់តាមសាលក្រម។ |

➢ **ស្មុំកូនពេញលេញ៖**

| | ស្មុំកូនពេញលេញ |
|---|---|
| ក | កូនសុំអាចជាអនីតិជន ឬនីតិជន ក៏បានដែរ។ |
| ខ | នៅក្នុងករណីដែលកូនសុំជាអនីតិជន ត្រូវតែមានការយល់ព្រមពីអ្នកមានអំណាចមេបាប៉ុណ្ណោះ (ក្នុងករណីដែលឪពុកម្ដាយលែងលះគ្នា មានតែឪពុក ឬម្ដាយតែម្ខាងប៉ុណ្ណោះ ដែលជាអ្នកមានអំណាចមេបាលើកូនជាអនីតិជន)។ |
| គ | ពុំផ្ដាច់ចំណងញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើតទេ។ |
| ឃ | ការកាត់កាល់មានពីរប្រភេទ ។ |
| ង | ១. ការកាត់កាល់តាមការព្រមព្រៀង ៖ តុលាការសម្រេចជាដីកាសម្រេច និង ២.ការកាត់កាល់តាមពាក្យបណ្ដឹង ៖ តុលាការសម្រេចជា សាលក្រម។ |

## ២.២. សារប្រយោជន៍ស្មុំកូន

ស្មុំកូនបានផ្ដល់ផលប្រយោជន៍ជាច្រើន ចំពោះបុគ្គលដែលចង់បានកូនមកធ្វើការចិញ្ចឹមដោយផ្ទាល់ខ្លួន និងកូនដែលមិនមានការថែទាំគ្រប់គ្រាន់ ឱ្យក្លាយទៅជាបុគ្គលដែលមានគ្រួសារមួយពេញលេញ។

ស្មុំកូនមានគោលបំណងចម្បងក្នុងការធានាបាននូវឧត្តមប្រយោជន៍ និងការការពារសិទ្ធិជាមូលដ្ឋានរបស់ក្មេងដូចជា៖ កុមារដែលមានឪពុកម្ដាយក្រីក្រ ដែលត្រូវការកិច្ចការពារពិសេស ដើម្បីធ្វើឱ្យពួកគេបានរស់នៅក្នុងមជ្ឈដ្ឋានសមស្រប ឬការអភិវឌ្ឍ ក្នុងបរិយាកាសគ្រួសារថ្មីមួយប្រកបដោយសុភមង្គល សេចក្ដីស្រឡាញ់ និងការយោគយល់។ លើសពីនេះទៅទៀត ដោយមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់ស្ថាប័នជាតិដែលជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញឱ្យកុមារកំព្រាទាំងឡាយទទួលបានការរស់នៅក្នុងមជ្ឈដ្ឋានគ្រួសារថ្មីមួយដែលពោរពេញទៅដោយករុណាធម៌ ការយកចិត្តទុកដាក់ ការទទួលខុសត្រូវនានា ដើម្បីឱ្យកុមារទទួលបានអនាគតភ្លឺស្វាង ដូចកុមារដទៃ។

### ២.២.១. ចំពោះសង្គម

ការធានាឧត្តមប្រយោជន៍ និងកិច្ចការពារសិទ្ធិកុមារដែលជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា ដែលត្រូវគិតគូរឱ្យកុមារមានការរីកចម្រើន ធំធាត់ និងអភិវឌ្ឍនៅក្នុងគ្រួសារមួយដ៏ល្អប្រកបដោយភាពកក់ក្ដៅ និងគ្មានការបំពានសិទ្ធិ។

ផ្ទុយមកវិញ បើការទុកដាក់កុមារនៅក្នុងគ្រួសារមួយដែលមិនមានលក្ខណៈសមស្រប វានឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កុមារជាក់ជាមិនខាន ដែលជាកត្តានាំឱ្យជះឥទ្ធិពលដល់សង្គមនាពេលអនាគត ព្រោះថាកុមារ គឺជាអនាគតសសរទ្រូងសម្រាប់ស្នងប្រទេសជាតិ។ ម៉្យាងវិញទៀត ការណ៍នេះក៏បានធ្វើឱ្យអត្រានៃកុមារកំព្រាបានថយចុះ ព្រមទាំងធ្វើឱ្យសង្គមទាំងមូលទទួលបានការរីកចម្រើនដូចជា កត្តាសេដ្ឋកិច្ច កត្តាអប់រំ កត្តាផ្សេងៗទៀតដែលបានផ្តល់ផលប្រយោជន៍ជាច្រើនដល់សង្គមជាតិ។ ដូចនេះ យើងទាំងអស់គ្នា គួរតែយកចិត្តទុកដាក់ទៅលើកុមារឱ្យបានច្រើន ដើម្បីឱ្យកុមារទាំងអស់ទទួលបានគ្រួសារមួយដែលសមស្របក្នុងការរស់នៅ ដែលជាកត្តាដ៏សំខាន់ដែលជំរុញឱ្យប្រទេសជាតិមានការអភិវឌ្ឍ រីកចម្រើនទៅថ្ងៃអនាគត។

**២.២.២. ចំពោះបុគ្គល**

សុំកូនបានផ្តល់ផលប្រយោជន៍ជាច្រើន ដែលអាចធ្វើឱ្យកុមារមានទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនជាអចិន្ត្រៃយ៍ និងរវាងកូនចិញ្ចឹមនឹងឪពុកម្តាយចិញ្ចឹមដោយបង្កើតជាគ្រួសារមួយពេញលេញ។

**ក. ចំពោះឪពុកម្តាយចិញ្ចឹម**

ឪពុកម្តាយចិញ្ចឹម ជាកត្តាដែលទទួលបានការគ្រប់គ្រងថែរក្សាលើកូនសុំដោយពេញលេញ ដូចជាកូនបង្កើតរបស់ខ្លួនក្នុងការការពារសិទ្ធិសេរីភាពរបស់កូនសុំ និងទទួលបានសិទ្ធិក្នុងការធានាដល់អត្ថប្រយោជន៍ និងករណីយកិច្ចនានាដែលអាចធ្វើទៅបានតាមលទ្ធភាព។ ជាពិសេស ឪពុកម្តាយចិញ្ចឹមមានអំណាចមេបាលើកូនសុំនោះ និងមានកាតព្វកិច្ចចាត់ចែងរាល់អ្វីដែលជាតម្រូវការរបស់ខ្លួន។ ប៉ុន្តែការប្រើប្រាស់នូវតម្រូវការនោះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់កូនសុំនោះ ដើម្បីធ្វើជាការបម្រើផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ។

កូនចិញ្ចឹម ជាកត្តាដែលបង្កើតឱ្យមានអានុភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម គឺកូនសុំត្រូវតែកាត់ផ្តាច់ចំណងញាតិភាពជាមួយឪពុកម្តាយបង្កើត ហើយកូនសុំត្រូវតែទទួលបាននូវសិទ្ធិ និងករណីយកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ រីឯអំណាចមេបាត្រូវប្រគល់ទៅឱ្យឪពុកម្តាយចិញ្ចឹមជាអ្នកទទួលបន្ទុកគ្រប់គ្រងថែរក្សា។ ជាពិសេស កូនសុំនោះទទួលបានគ្រួសារថ្មីមួយដែលពេញលេញប្រកបទៅដោយសុភមង្គល។

# ជំពូកទី ២
# ស្ទុំកូនពេញលេញ

# ជំពូកទី ២

# សុំកូនពេញលេញ

ជាការពិតណាស់ របបសុំកូន គឺជារបបទទួលស្គាល់បុគ្គលទាំងឡាយណា ដែលគ្មានទំនាក់ទំនងសាច់ញាតិ ដោយបង្កើតនូវទំនាក់ទំនងឪពុកម្ដាយនិងកូនសុំ ដូចឪពុកម្ដាយនិងកូនបង្កើតដែរ។

គោលបំណងនៃការរបបសុំកូន[12]៖

- គ្រួសារ ដែលគ្មានអ្នកស្នងអាចរកអ្នកស្នងបានតាមរយៈការសុំកូន ( ឱ្យស្នងអាជីវកម្ម -ល- ) គ្រួសារសន្តតិកម្ម ទ្រព្យសម្បត្តិ ជាអាទិ៍។
- ចំពោះគ្រួសារដែលគ្មានកូន អាចរកកូនបាន ( ដើម្បីឱ្យកូននោះ មើលថែរក្សា និងផ្គត់ផ្គង់អាហារកិច្ចនៅពេលដែរខ្លួនចាស់ជាអាទិ៍)។
- រកឪពុកម្ដាយសម្រាប់កុមារកំព្រា។

អនុលោមតាមគន្ថីទី៧ ស្ដីពីញាតិ ជំពូកទី៤ ផ្នែកទី២ នៃក្រមរដ្ឋប្បវេណី ការសុំកូនត្រូវបានបែងចែកជា២ប្រភេទ៖ គឺ សុំកូនពេញលេញ និងសុំកូនធម្មតា[13]។

ការបង្កើតនូវរបបសុំកូននេះឡើង គឺដើម្បីរក្សាការពារ និងផ្ដល់ផលប្រយោជន៍ដល់កូនសុំទាំងឡាយណាដោយទទួលបានភាពកក់ក្ដៅពីក្រុមគ្រួសារថ្មីរបស់កូនសុំនោះ តួយ៉ាងដើម្បីអាចឱ្យតុលាការធ្វើការពិចារណា នូវសិទ្ធិអត្ថិភាពរបស់ប្ដីប្រពន្ធដែលបានដាក់ពាក្យស្នើសុំ និងការពារផលប្រយោជន៍របស់កូនសុំនោះ ដូច្នេះតាមការកំណត់របស់ច្បាប់ គឺត្រូវមានការត្រួតពិនិត្យយ៉ាងម៉ត់ចត់ហ្មងដោយតុលាការ ហើយអាចចេញនូវដីកាសម្រេចអំពីការសុំកូនបាន លុះត្រាតែបានបំពេញនូវលក្ខខណ្ឌចាំបាច់គឺ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ ដើម្បីជាគ្រឹះមូលដ្ឋាននិងការវិនិច្ឆ័យមួយដែលមានភាពប្រាកដច្បាស់លាស់ ហើយមានអនុលោមភាពតាមច្បាប់។

## ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃសុំកូនពេញលេញ

### ១.១ គោលបំណងនៃការបង្កើតរបបសុំកូនពេញលេញ

ការសុំកូន គឺជាការបង្កើតទំនាក់ទំនងញាតិតាមផ្លូវច្បាប់រវាងបុគ្គលដែលជាឪពុកម្ដាយ និងកូនសុំ។ ទំនាក់ទំនងនេះក៏មានគោលបំណងបង្កើតឱ្យមាននូវការទទួលបន្តមត៌កតាមរយៈសន្តតិកម្ម និងករណីយកិច្ចរវាងភាគីនៃសុំកូន ដែលដូចគ្នាទៅនឹងទំនាក់ទំនងញាតិលោហិតផងដែរ (មាត្រា៩៤០ នៃក្រមរដ្ឋប្បវេណី)។

យោងតាមក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ របបសុំកូនត្រូវបានបែងចែកជាពីរ គឺសុំកូនពេញលេញ និងសុំកូនធម្មតា។

[12] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, *យល់ដឹងផ្នែកច្បាប់៖ ការសុំកូន* (២២ មេសា ២០២០), https://ciclg.com/kh/article/72 (ថតចម្លងថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២)។

[13] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៧ ដល់ ១០៤២។

ដោយពិនិត្យលើលក្ខណៈទូទៅ របបសុំកូនទាំងពីរមានគោលបំណងដូចគ្នាគឺ ការបង្កើតឱ្យមានទំនាក់ទំនងញាតិរវាងឪពុកម្ដាយចិញ្ចឹម និងឪពុកម្ដាយបង្កើត។ ប៉ុន្តែក្រៅពីលក្ខណៈដូចគ្នានេះ គោលបំណងនៃការបែងចែករបបសុំកូនមានដូចខាងក្រោម[14]៖

**១.១.១. ការពារផលប្រយោជន៍របស់កូនសុំ**

របបសុំកូនពេញលេញត្រូវបានបង្កើតដោយយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការការពារផលប្រយោជន៍របស់កូនសុំ។ រាល់លក្ខខណ្ឌនីមួយៗមានភាពតឹងរឹងដើម្បីធានាការបង្កើតរបបសុំកូនអាចធ្វើឱ្យអនាគតរបស់កូនសុំមានភាពប្រសើរជាងការរស់នៅជាមួយគ្រួសារបង្កើត។ ដោយឡែក របបសុំកូនធម្មតាវិញ យើងពុំឃើញមានលក្ខខណ្ឌតឹងរឹង ដូចសុំកូនពេញលេញឡើយ។

ដោយ យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ( UNCRC ) មាត្រា៥ កថាខណ្ឌទី១ ឧត្តមប្រយោជន៍របស់កុមារត្រូវគិតគូរជាចម្បង[15]។ ក្រៅពីលក្ខខណ្ឌផ្សេងៗទៀត ប្រសិនបើគោលបំណងនៃការសុំកូននោះពុំមែនជាការការពារផលប្រយោជន៍កុមារ សុំកូនពេញលេញមិនត្រូវអនុញ្ញាតឡើយ។ ផ្ទុយពីនេះ របបសុំកូននោះពុំតម្រូវឱ្យមានស្ថានភាពចាំបាច់ដើម្បីផលប្រយោជន៍កូនសុំទេ។ កូនសុំក្នុងរបបនេះអាចជានីតិជន ឬអនីតិជនហើយកូនសុំធម្មតានៅតែរក្សាទំនាក់ទំនងរវាងឪពុកម្ដាយបង្កើត និងកូនសុំដដែល ហេតុនេះករណីយកិច្ចរវាងកូនសុំ និងឪពុកម្ដាយបង្កើត ព្រមទាំងញាតិភាពពុំត្រូវបានកាត់ផ្ដាច់ទេ។

**១.១.២. ការផ្ដល់នូវគ្រួសារថ្មីដ៏ល្អ**

ថ្វីត្បិតតែទំនាក់ទំនងសុំកូន ត្រូវបានបង្កើតឡើងក្រោមផ្លូវច្បាប់សារធាតុនៃនីតិជន ប៉ុន្តែទំនាក់ទំនងនេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈដែលត្រូវយកចិត្តទុកដាក់។ របបសុំកូនពេញលេញត្រូវបានបង្កើតឡើងតាមផ្លូវតុលាការ ដើម្បីតុលាការអាចវិនិច្ឆ័យអំពីភាពសមស្របនៃការសុំកូន ចៀសវាងការអនុញ្ញាតឱ្យភាគីបង្កើតទំនាក់ទំនង សុំកូនឯកជនដោយគ្មានការត្រួតពិនិត្យ។

គ្រួសារថ្មីជាទីបង្អែករបស់កុមារ ត្រូវបានពិចារណាយ៉ាងហ្មត់ចត់ដោយតុលាការ អំពីលទ្ធភាពផ្នែកសេដ្ឋកិច្ច ភាពចាស់ទុំក្នុងការអប់រំថែរក្សាកូន។ ហេតុនេះ កុមារនឹងទទួលបានគ្រួសារមួយកក់ក្ដៅ ថ្វីត្បិតតែវាពុំមែនជាគ្រួសារបង្កើតរបស់កុមារយ៉ាងណាក្ដី។

## ផ្នែកទី២ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

ដើម្បីបង្កើតកូនសុំពេញលេញបាន លុះត្រាតែបំពេញតាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ ហើយមានលក្ខខណ្ឌសំខាន់មួយចំនួន ដែលលក្ខខណ្ឌទាំងនេះមានដូចជា លក្ខខណ្ឌទាក់ទងនឹងអាយុរបស់ឪពុកម្ដាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់ភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ -ល- ដោយការបង្កើតកូនសុំពេញ

[14] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤០។
[15] អនុសញ្ញាស្តីពីសិទ្ធិកុមារ, សេចក្តីសម្រេចចិត្ត លេខ ៤៤/២៥, ២០ វិច្ឆិកា ១៩៨៩, មាត្រា៥ កថាខណ្ឌទី១។

លេញគឺ មិនមែនមានតែភាគីម្ខាងៗនោះទេ គឺមានចំពោះឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ក៏ដូចជាភាគីគឺកូនសុំ និងនៅមានលក្ខខណ្ឌដទៃទៀតមួយចំនួនផងដែរ។

**២.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតសុំកូនពេញលេញ**

សុំកូនពេញលេញ សំដៅដល់ការសុំអនីតិជន ដែលមានអាយុក្រោម ៨ឆ្នាំយកមកធ្វើជាកូនសុំ ដោយមានការបង្កើតទំនាក់ទំនងឪពុកម្តាយ នឹងកូនជាមួយឪពុកម្តាយចិញ្ចឹម និងបញ្ចប់ញាតិភាពនៃញាតិលោហិត រួមទាំងសិទ្ធិ និងកាតព្វកិច្ចរវាងកុមារ និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលកុមារ ហើយការសុំនេះត្រូវធ្វើតាមសេចក្តីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់។ ដើម្បីជាផលប្រយោជន៍ដល់កុមារ ច្បាប់បានកំណត់អំពីលក្ខណៈសម្បត្តិរបស់សហព័ទ្ធ និងភាពចាំបាច់ក្នុងការបង្កើតនូវរបបសុំកូនពេញលេញនេះ ដែលមានគោលដៅកំណត់អំពីអត្ថិភាព និងការត្រួតពិនិត្យយ៉ាងតឹងរឹង ដើម្បីអាចចេញសេចក្តីសម្រេចអំពីការសុំកូនពេញលេញ។

**២.១.១. លក្ខខណ្ឌពាក់ព័ន្ធនឹងឪពុកម្តាយចិញ្ចឹម**

ការសុំកូនពេញលេញអាចបង្កើតឡើងទៅបានលុះត្រាតែសហព័ទ្ធ ពោលគឺឪពុកម្តាយចិញ្ចឹមទាំងពីរនោះត្រូវមានកម្រិតជីវភាពសមរម្យ និងមានលទ្ធភាពមើលថែ និងផ្តល់ភាពកក់ក្តៅដល់កូនសុំសម្រាប់ការផ្តល់នូវក្រុមគ្រួសារថ្មីដល់កុមារនោះ ហើយធ្វើយ៉ាងផ្តល់ការការពារ និងស្រឡាញ់កូនសុំដូចឪពុកម្តាយបង្កើត និងកូនបង្កើតផងដែរ។ តាមលក្ខខណ្ឌដែលច្បាប់បានកំណត់ឪពុកម្តាយចិញ្ចឹមត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចក្លាយជាឪពុកម្តាយបាន តម្រូវឱ្យបំពេញនូវលក្ខខណ្ឌដូចខាងក្រោម[16]៖

**ក. ស្ថានភាពឋានៈបុគ្គលរបស់ឪពុកម្តាយចិញ្ចឹម**

ផ្អែកតាមក្រមរដ្ឋប្បវេណី បានបញ្ញត្តិអំពីបុគ្គលដែលក្លាយជាឪពុក ឬម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ[17]។

ដោយមូលហេតុថា គោលបំណងនៃសុំកូនពេញលេញ គឺផ្តល់ផលប្រយោជន៍ដល់កូនសុំឱ្យទទួលបានគ្រួសារមួយដែលមានភាពពេញលេញទទួលបានការមើលថែ ដូចឪពុកម្តាយបង្កើតដែលមានការចូលរួមពីឪពុកចិញ្ចឹមផង និងម្តាយចិញ្ចឹមផង ហេតុនេះប្តី ឬប្រពន្ធណាម្ខាងដែលមិនមែនជាសហព័ទ្ធពុំអាចក្លាយជាឪពុកម្តាយចិញ្ចឹមបានទេ។

**ខ. អាយុរបស់ឪពុកម្តាយចិញ្ចឹម**

យោងតាមមាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី ពុំបានបញ្ជាក់ថាឪពុកម្តាយត្រូវមានអាយុ២៥ឆ្នាំ គិតចាប់ពីពេលណានោះទេ ប៉ុន្តែគោលគំនិតនេះ គេគិតចាប់ពីពេលដែលកើតឡើងនូវអានុភាពដីកាសម្រេច ដែលថាបុគ្គលដែលដាក់ពាក្យសុំត្រូវមានអាយុ២៥ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច២០ឆ្នាំ ទើបមាន

[16] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៨ ដល់ ១០១២។
[17] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៨ កថាខណ្ឌទី១។

សិទ្ធិដាក់ពាក្យស្នើសុំបង្កើតកូនស្មុំពេញលេញបាន[18]។ ប្រសិនបើអាយុរបស់ឪពុកម្ដាយចិញ្ចឹមតិចពេក នោះលទ្ធភាព និងបទពិសោធន៍ក្នុងការថែរក្សាកូនសុំនោះនៅមានកម្រិត ដែលកូនសុំនោះនឹងមិនអាចទទួលការថែទាំដែលមិនត្រឹមត្រូវ ម៉្យាងវិញទៀត ពួកគេមិនអាចផ្ដល់នូវគ្រួសារដែលល្អប្រសើរជាងឪពុកម្ដាយបង្កើតបានហេតុនេះហើយតម្រូវឱ្យមានការពិនិត្យទៅលើអាយុរបស់ឪពុកម្ដាយចិញ្ចឹមយ៉ាងតឹងរឹងនោះ។

**ឧទាហរណ៍៖** បុរស **ក** អាយុ៤៥ឆ្នាំ និងនារី **ខ** អាយុ៤៣ឆ្នាំ អ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់រយៈពេល១៥ឆ្នាំ ចាប់តាំងពីឆ្នាំ២០១០មកម្ល៉េះ ប៉ុន្តែអ្នកទាំងពីរពុំមានកូនម្នាក់ឡើយ។ ដោយមូលហេតុចង់បានកូនសម្រាប់ស្នងមត៌ក និងមើលថែពេលចាស់ទៅ បុរស **ក** និងនារី **ខ** បានពិភាក្សាគ្នាចង់សុំកូនពេញលេញឈ្មោះ **ពិសិដ្ឋ** ជាអនីតិជន ដែលមានអាយុ៤ឆ្នាំ។ ដូច្នេះតាមកម្រិតអាយុរបស់សហព័ទ្ធ អ្នកទាំងពីរ នេះអាចមានលទ្ធភាពក្នុងការចិញ្ចឹមបីបាច់ និងថែរក្សាកូនសុំនោះយ៉ាងកក់ក្ដៅ ផ្អែកលើបទពិសោធន៍ដែលលក្ខខណ្ឌច្បាប់បានកំណត់។

**គ. គោលការណ៍សហការរបស់ឪពុកម្ដាយចិញ្ចឹម**

បុគ្គលដែលក្លាយជាឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។ ច្បាប់មានគោលបំណងការពារ និងផ្ដល់ផលប្រយោជន៍ដល់កូនស្មុំ ដើម្បីឱ្យកុមារទទួលបាននូវក្រុមគ្រួសារថ្មី មានភាពកក់ក្ដៅពីឪពុកម្ដាយចិញ្ចឹម ដូចនឹងឪពុកម្ដាយបង្កើតដែរ តួយ៉ាង ប្ដីនិងប្រពន្ធត្រូវមានការសហការ និងឯកភាពយល់ព្រមរវាងប្ដីនិងប្រពន្ធ បើមិនដូច្នេះទេប្ដី ឬប្រពន្ធតែម្ខាងមិនអាចក្លាយជាឪពុក ឬម្ដាយចិញ្ចឹមគេបានឡើយ បើសហព័ទ្ធម្ខាងទៀតមិនមែនជាឪពុក ឬម្ដាយចិញ្ចឹមរបស់កូនសុំនោះ[19]។

ជាអញ្ញត្រកម្ម ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ការលើកលែងចំពោះសហព័ទ្ធម្ខាងដែលក្លាយជាឪពុក ឬម្ដាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត ពោលគឺប្រសិនបើសហព័ទ្ធម្ខាងចង់សុំកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំនោះ ពុំបាច់មានការយល់ព្រម ឬឯកភាពពីសហព័ទ្ធម្ខាងទៀតឡើយ ហើយកូនចិញ្ចឹមនោះ យើងអាចហៅថា គឺជាកូនចុង។

**ឧទាហរណ៍៖** លោក **ដារ៉ា** គឺជាបុរសពោះម៉ាយមានកូនស្រីម្នាក់ឈ្មោះ **ធីតា**។ ថ្ងៃមួយ លោក **ដារ៉ា** មានទំនាក់ទំនងជាមួយនឹងនារីម្នាក់ឈ្មោះ លោកស្រី **សុវណ្ណា** អ្នកទាំងពីរក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ដូច្នេះ **ធីតា** ត្រូវជាកូនចុងរបស់លោកស្រី **សុវណ្ណា** ដោយលោកស្រី **សុវណ្ណា** មិនចាំបាច់សហការ ឬសុំការយល់ព្រមពីលោក **ដារ៉ា** ទេ ពោលគឺឱ្យតែអ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារួចហើយ សហព័ទ្ធម្ខាង គឺជាឪពុកម្ដាយចុងនៃកូននោះ។

[18] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៩។
[19] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៨ កថាខណ្ឌទី១។

### ២.១.២. លក្ខខណ្ឌពាក់ព័ន្ធនឹងឪពុកម្ដាយបង្កើត

#### ក. ការយល់ព្រមរបស់ឪពុកម្ដាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលនឹងក្លាយជាកូនសុំនោះ យោងតាមមាត្រា១០១១ នៃក្រមរដ្ឋប្បវេណី។ ដោយសារតែគោលបំណងការសុំកូនពេញលេញ ត្រូវកាត់ផ្ដាច់នូវទំនាក់ទំនងសាច់ញាតិលោហិតផ្ទាល់នៃឪពុកម្ដាយបង្កើត និងដាក់បញ្ចូលកូនសុំនោះចូលក្នុងគ្រួសារថ្មីជាមួយឪពុកម្ដាយចិញ្ចឹម ដែលច្បាប់តម្រូវឱ្យតុលាការធ្វើការសាកសួរការបង្ហាញឆន្ទៈយល់ព្រមពីសំណាក់ឪពុកម្ដាយបង្កើតផ្ទាល់ ប្រសិនជាកូនសុំនោះ មានឪពុកម្ដាយបង្កើត។

ការយល់ព្រមរបស់ឪពុកម្ដាយបង្កើតអាចដកវិញបាននៅពេលណាក៏បាន មុនពេលដីកាសម្រេចបង្កើតសុំកូនពេញលេញចូលជាស្ថាពរ ក្នុងករណីឪពុកម្ដាយបង្កើតរបស់កូនសុំបានដកនូវការយល់ព្រមតុលាការ ត្រូវលើកចោលពាក្យសុំបង្កើតនូវសុំកូនពេញលេញ លើកលែងតែការដកការយល់ព្រមនោះបំពានដល់ផលប្រយោជន៍ធ្ងន់ធ្ងររបស់កូនសុំនោះ ដូចមូលហេតុដែលមានចែងក្នុងមាត្រា១០១១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

ច្បាប់បានកំណត់ ចំពោះករណីលើកលែង ដែលមិនចាំបាច់តម្រូវឱ្យមានការយល់ព្រមពីឪពុកម្ដាយបង្កើតឡើយ មានក្នុងករណីដូចខាងក្រោម[20]៖

- **ឪពុកម្ដាយមិនអាចបង្ហាញឆន្ទៈបាន៖** ការយល់ព្រមរបស់ឪពុកម្ដាយបង្កើតពិតជាចាំបាច់សម្រាប់អាចឱ្យតុលាការចេញដីកាសម្រេចអំពីការបង្កើតសុំកូនពេញលេញ ប៉ុន្តែប្រសិនជាឪពុកម្ដាយបង្កើត មិនអាចទាក់ទងបាន ឬមិនដឹងថាពួកគាត់រស់នៅទីណា ឬមានបញ្ហាផ្លូវចិត្ត (វិបល្លាសស្មារតី) ឬមនុស្សរុក្ខជាតិ ដែលមិនអាចសម្រេចក្នុងការបង្ហាញបាននោះ តុលាការមិនចាំបាច់គោរពលើលក្ខខណ្ឌយល់ព្រមរបស់ឪពុកម្ដាយបង្កើតឡើយ។
- **ការប្រើប្រាស់ហិង្សា៖** ករណីដែលឪពុកម្ដាយបង្កើតតែងតែប្រើអំពើហិង្សា ឈ្លោះគ្នា ធ្វើឱ្យប៉ះពាល់ដល់សតិអារម្មណ៍របស់កុមារយ៉ាងខ្លាំង ដែលអាចជះឥទ្ធិពលដល់អនាគតពេល ធ្វើឱ្យក្មេងមានអារម្មណ៍ភ័យខ្លាច និងអាចយកគំនូរតាម ហើយប្រើហិង្សាទៅអ្នកដទៃ ជាពិសេសក្មេងមិនអាចផ្ដោតការយកចិត្តទុកដាក់ក្នុងការសិក្សា អាចឈានទៅដល់ការរត់ចេញពីផ្ទះដោយសារតែក្រុមគ្រួសារគ្មានភាពកក់ក្ដៅ និងគ្មានសុភមង្គល ដែលជាមូលហេតុអាចឱ្យអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិ អាចដកហូតសិទ្ធិអំណាចមេបាពីឪពុកម្ដាយបង្កើតនោះផ្ទេរទៅឱ្យឪពុកម្ដាយចិញ្ចឹម ឬអង្គភាពដែលទទួលបន្ទុកក្នុងការថែរក្សាកុមារ។

[20] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១១ វាក្យខណ្ឌទី២។

- **ការបោះបង់ចោលកូនដោយគំនិតទុច្ចរិត៖** សំដៅទៅលើឪពុកម្ដាយបង្កើតនោះ គ្មានទំនួលខុសត្រូវលើកាតព្វកិច្ចរបស់ខ្លួន ដោយគាត់មានចេតនាបោះបង់កូនចោលនៅតាមមន្ទីរពេទ្យ ឬនៅតាមផ្លូវទីសាធារណៈ ដោយមិនខ្វល់ពីសុវត្ថិភាពរបស់កូន ធ្វើយ៉ាងដើម្បីរួចផុតពីកាតព្វកិច្ចជាឪពុកម្ដាយបង្កើត។
- ហេតុផ្សេងទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះយ៉ាងធ្ងន់ធ្ងរ[21]៖ (១) ករណីឪពុកម្ដាយបង្កើតនោះ យកកូនបង្កើតរបស់ខ្លួនឱ្យទៅធ្វើការទៅតាមហាងសហគ្រាសល្មើសនឹងច្បាប់ការងារ ឬបង្ខាប់ឱ្យដើរសុំទាន ឬលួចបន្លំអ្នកដទៃ ជាអាទិ៍ ដែលធ្វើឱ្យក្មេងលែងចង់រៀនសូត្រ និងបាត់បង់ការអភិវឌ្ឍរូបរាងកាយ ឬអាចបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតកុមារ។ (២) ការកេងប្រវ័ញ្ចលើកូន ដោយយកកូនទៅលក់ ឬធ្វើពេស្យាចារ ក្នុងការប្រកបអាជីវកម្មខុសច្បាប់ ដោយដោះដូរជាសាច់ប្រាក់ ឬជាវត្ថុអ្វីមួយ ដែលធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ប្រពៃណី និងសេចក្ដីថ្លៃថ្នូរ ច្បាប់ជាតិ អន្តរជាតិក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ។

### ខ.ស្ថានភាពឋានៈបុគ្គលរបស់ឪពុកម្តាយបង្កើត

ការបង្កើតនូវរបបសុំកូនពេញលេញ គឺដើម្បីផ្ដល់គ្រួសារថ្មីមួយដែលយកចិត្តទុកដាក់ដល់កូនសុំ និងការពារចិញ្ចឹមបីបាច់ ផ្ដល់នូវការស្រឡាញ់ដូចជាសាច់ញាតិបង្កើត ផ្ដល់ការអប់រំ និងអាហារហូបចុក ដែលបញ្ចប់នូវទំនាក់ទំនងសាច់លោហិតពីឪពុកម្ដាយបង្កើត ដូច្នេះ តុលាការត្រូវពិនិត្យចាំបាច់ឱ្យឃើញពីការបង្ហាញឆន្ទៈយល់ព្រមរបស់ឪពុកម្ដាយបង្កើតយ៉ាងតឹងរឹងបំផុត ដែលអាចបង្កើតនូវរបបសុំកូនពេញលេញបាន។

ប្រសិនបើឪពុកម្ដាយបង្កើតមិនស្ថិតក្នុងស្ថានលំបាកខ្លាំង និងមិនអាចគ្រប់គ្រងមើលថែរក្សាកុមារនោះបាន ឬស្ថិតក្នុងស្ថានពិសេសណាមួយនោះ សុំកូនពេលលេញក៏មិនត្រូវបង្កើតឡើងបានដែរ។

### ២.១.៣. លក្ខខណ្ឌពាក់ព័ន្ធនឹងកុមារដែលក្លាយជាកូនសុំ

នៅក្នុងក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិណាមួយចែងអំពីការសុំកូនបានចំនួនប៉ុន្មាន និងការស្នើសុំបានប៉ុន្មានលើកនោះទេ តែគេអាចសង្កេតឃើញថាការសម្រេចសេចក្ដី គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម។

ចំពោះកុមារដែលនឹងក្លាយជាកូនសុំវិញ ឃើញច្បាស់ថាច្បាប់មិនបានកំណត់ពីលក្ខខណ្ឌអ្វីច្រើនទេ គឺផ្ដោតតែលើចំណុចសំខាន់ ២យ៉ាងគឺ អាយុរបស់កុមារនោះ និងស្ថានភាពដែលកុមារនោះរស់នៅសព្វថ្ងៃជាមួយនឹងឪពុកម្ដាយបង្កើត ឬជាអ្នកមានអំណាចមេបាលើគេតែប៉ុណ្ណោះ ដែលលក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍កុមារ[22]។

[21] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១១។

[22] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១១ ដល់ ១០១២។

**ក. លក្ខខណ្ឌពាក់ព័ន្ធនឹងអាយុកូនសុំ**

ជាគោលការណ៍កូនសុំត្រូវមានអាយុតិចជាង៨ឆ្នាំ[23]។ ហើយរបបកូនសុំពេញលេញ គឺជារបបបង្កើតឡើងរវាងឪពុកម្ដាយចិញ្ចឹម និងកុមារក្នុងការបង្កើតញាតិថ្មី និងផ្ដាច់កូនសុំនោះពីញាតិចាស់។ ប៉ុន្តែជាបដិបញ្ញត្តិ តុលាការអាចបង្កើតសុំកូនពេញលេញ ទោះបីជាកូនសុំមានអាយុចាប់ពី៨ឆ្នាំឡើងទៅក៏ដោយ យ៉ាងណាមិញជាយុត្តិសាស្ត្ររបស់តុលាការ អាចកំណត់អំពីស្ថានភាពនាពេលអនាគតខាងមុខបាន។

**ឧទាហរណ៍៖ ជីវ៉ា** ជាប្ដី និង **សុភាព** ជាប្រពន្ធ បានទទួលយក **មករា** មកចិញ្ចឹមតាំងពី **មករា** មានអាយុ២ឆ្នាំមកម្ល៉េះ តែបច្ចុប្បន្ននេះ **មករា** មានអាយុ១៣ឆ្នាំទៅហើយ ដោយសារតែកង្វះចំណេះដឹងផ្នែកច្បាប់ អ្នកទាំងពីរមិនបានដាក់ពាក្យស្នើសុំ **មករា** ជាកូនចិញ្ចឹមត្រឹមត្រូវតាមច្បាប់ឡើយ ហេតុនេះ អ្នកទាំងពីរទើបតែដឹងអំពីរបបសុំកូនពេញលេញ ក៏បានដាក់ពាក្យស្នើសុំទៅតុលាការមានសមត្ថកិច្ច។ ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការដោយឃើញថា **ជីវ៉ា** និង **សុភាព** បានទទួលចិញ្ចឹម **មករា** តាំងពីអាយុ២ឆ្នាំ ដូច្នេះតុលាការអាចសម្រេចសេចក្ដីអនុញ្ញាតឱ្យបង្កើតនូវរបបសុំកូនពេញលេញបាន។

**ខ. លក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍កុមារ**

សុំកូនពេញលេញអាចបង្កើតឡើងបាន ដោយមូលហេតុកូន ឬឪពុកម្ដាយចិញ្ចឹមមានស្ថានភាពពិបាកខ្លាំង ស្ថានភាពគ្រួសារក្រីក្រខ្លាំង ឬមិនសមរម្យក្នុងការគ្រប់គ្រងថែរក្សាកុមារ មានបញ្ហាផ្នែករាងកាយ និងស្ថិតក្នុងស្ថានភាពពិសេស ដើម្បីការពារផលប្រយោជន៍របស់កូនសុំនោះ។

## ផ្នែកទី៣ ៖ លក្ខខណ្ឌទម្រង់នៃការបង្កើតសុំកូនពេញលេញ

ការបង្កើតសុំកូនពេញលេញ ត្រូវធ្វើឡើងតាមរយៈសេចក្ដីសម្រេច ហេតុនេះការបង្កើតសុំកូនពេញលេញត្រូវមានអន្តរាគមន៍ពីតុលាការដែលមានសមត្ថកិច្ច ដែលតុលាការត្រូវគោរពតាមនីតិវិធីដែលកំណត់ក្នុង ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងក្នុងការបង្កើតសុំកូនពេញលេញ ដោយផ្អែកតាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ដោយហេតុថាការបង្កើតទំនាក់ទំនងគតិយុត្តនេះ ឆន្ទៈរបស់គូភាគីពុំទាន់អាចមានអានុភាពតាមផ្លូវច្បាប់ សម្រាប់បង្កើតទំនាក់ទំនងឋានៈបុគ្គលឡើយ។ ក្រោយពីពាក្យសុំ ត្រូវបានដាក់ដោយត្រឹមត្រូវហើយ តុលាការចាត់ការលើនីតិវិធីដោយអនុលោមទៅតាមច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង និងត្រូវសម្រេចសេចក្ដីក្រោមទម្រង់ជាដីកាសម្រេច ដោយផ្អែកទៅលើលក្ខខណ្ឌដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង។

បុគ្គលដែលចង់បង្កើត សុំកូនពេញលេញត្រូវបំពេញទៅតាមលក្ខខណ្ឌទម្រង់ទៀត បើពុំដូច្នោះទេគេមិនចាត់ទុកថាបានបង្កើតសុំកូនឡើងទេ។ លក្ខខណ្ឌទម្រង់ គឺសំដៅដល់ការដាក់ពាក្យសុំទៅតុលាការ ដើម្បីសុំបង្កើតសុំកូនពេញលេញនេះ។ មុននឹងយើងអាចធ្វើការដាក់ពាក្យសុំបង្កើតសុំកូនពេញលេញ យើងក៏ត្រូវស្វែង

[23] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១០។

យល់ពីអ្នកដែលមានសិទ្ធិនៅក្នុងការដាក់ពាក្យ របៀបដាក់ពាក្យ ទម្រង់នៃពាក្យ សុំនោះ និងសមត្ថកិច្ចដែលមានតួនាទីទទួលពាក្យនោះ។

### ៣.១. ការវិវត្តនៃសង្គម

គិតចាប់ពីឆ្នាំ ១៩៨៩ ដល់ ២០០៧ មានច្បាប់ពីរសំខាន់ពាក់ព័ន្ធនឹងបញ្ហាស្មុំកូន រួមមាន៖ (១) ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ (ចាប់ពីមាត្រា១០៨ ដល់មាត្រា១២២) និង (២) ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ភាពខុសគ្នារវាងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧៖ (១) **ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩** ស្មុំកូនពុំត្រូវកម្រិតចំពោះបរិមាណនៃកូនស្មុំ ថែមទាំងមិនដាក់កំហិតចំពោះការស្នើសុំទៅតុលាការទៀត។ (២) **ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧** ស្មុំកូនត្រូវបានកម្រិតបរិមាណ ជាគោលការណ៍មិនឱ្យលើសពីពីរនាក់ ហើយត្រូវតែដាក់ពាក្យស្នើសុំទៅតុលាការ។ បច្ចុប្បន្នរាជរដ្ឋាភិបាលបានបង្កើតជា យន្តការក្នុងការទប់ស្កាត់ចំពោះការសុំ ត្រូវមានការធានាថា កុមារដែលជាកូនសុំត្រូវមានសិទ្ធិទទួលបាននូវការការពារ ដែលក្នុងនោះមានសិទ្ធិការពារទប់ស្កាត់ និងប្រឆាំងចំពោះការជិះជាន់ និងការរំលោភបំពានសិទ្ធិរបស់កុមារ។ លើសពីនេះ កុមារត្រូវរួចផុតអំពីការកេងប្រវ័ញ្ចនានា ដូចជាការរួចផុតពីការធ្វើពលកម្ម និងការរួចផុតពីអំពើកេងប្រវ័ញ្ចលើ សិទ្ធិស្មុំកូន ដែលមានន័យថា កូនស្មុំ ក៏មានសិទ្ធិគ្រប់គ្រាន់ទៅតាមផ្លូវច្បាប់ដូចកុមារដទៃទៀតដែរ។ ជាពិសេស រដ្ឋក៏ត្រូវទប់ស្កាត់នូវការជិះជាន់លើផ្លូវភេទ ការពង្រាត់ ការលក់ដូរ និងការជួញដូរកុមារ ជាដើម។

### ៣.២. ស្ថានភាពគ្រួសារ

បុគ្គលដែលអាចធ្វើការស្មុំកូនបានត្រូវតែមានលក្ខណៈសម្បត្តិសមស្របទៅតាមតម្រូវការនៃនីតិវិធីច្បាប់ ដែលបានចែងអំពី ទីលំនៅឋានអចិន្ត្រៃយ៍ ជីវភាព សីលធម៌ និងគុណធម៌ក្នុងការយកកូនមកចិញ្ចឹម ដែលស្ថិតនៅក្រោមការថែទាំដោយយកចិត្តទុកដាក់ ទោះបីជាកូនសុំមកនោះមិនមែនជាកូនបង្កើតរបស់ខ្លួនក៏ដោយ។ ជាក់ស្តែង ពួកគេត្រូវមានការផ្គត់ផ្គង់តាមលទ្ធភាពដែលអាចធ្វើទៅបានដូចជា ការផ្តល់ទៅលើការសិក្សាអប់រំ ការហូបចុកគ្រប់គ្រាន់ ការស្នាក់នៅល្អ ការលើកទឹកចិត្ត ការចិញ្ចឹមបីបាច់ថែរក្សា និងការការពារសិទ្ធិជាមូលដ្ឋានរបស់កុមារនោះជាចាំបាច់។ ម្យ៉ាងទៀត បុគ្គលដែលធ្វើការសុំកូននោះ មិនត្រូវសុំយកមកធ្វើជាអំពើអនាចារ ដើម្បីជាអត្ថប្រយោជន៍ផ្ទាល់ខ្លួននោះទេ។

### ៣.៣. ការដាក់ពាក្យសុំ

កូនស្មុំពេញលេញមានអានុភាពតាមច្បាប់ លុះត្រាតែបានបង្កើតតាមផ្លូវតុលាការ គឺមានន័យថាបុគ្គលដែលមានបំណងបង្កើតកូនស្មុំពេញលេញ ត្រូវតែដាក់ពាក្យសុំទៅតុលាការ តាមរយៈពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយ ចិញ្ចឹមត្រូវដាក់ពាក្យសុំរួមគ្នាដោយសហការរវាងប្តីប្រពន្ធ ទៅតុលាការដែលមានសមត្ថកិច្ច

នោះ គឺសាលាដំបូង ដែលមានសមត្ថកិច្ចលើលំនៅដ្ឋានរបស់អ្នកដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹម ឬ អាចយកភាគីឪពុកម្ដាយបង្កើត ឬអ្នកមានសិទ្ធិអាណាព្យាបាលទូទៅជាភាគីម្ខាងទៀត។ ក្នុងករណីដែលប្ដី ឬ ប្រពន្ធតែម្ខាង ជាអ្នកដាក់ពាក្យសុំបង្កើតសុំកូនទៅតុលាការ នោះតុលាការត្រូវលើកចោលពាក្យសុំដោយដីកាសម្រេច ព្រោះជាពាក្យសុំដែលផ្ទុយនឹងច្បាប់[24]។

ពាក្យសុំបង្កើតកូនពេញលេញ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បានលើកលែងតែក្នុងករណីដែលមានប្បញ្ញត្តិពិសេសក្នុងច្បាប់ ហើយនៅក្នុងពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖

ក-ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ-ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងៗទៀតរបស់តុលាការ ដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។

ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្ដីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនេះ ត្រូវបានកំណត់ថាជាពាក្យសុំ។

បន្ថែមពីលើនេះ អ្នកដាក់ពាក្យសុំត្រូវបង្ហាញនៅក្នុងពាក្យសុំរបស់ខ្លួន ពីអង្គហេតុដែលជាមូលហេតុនៃការទាមទារដូចជា[25]៖

- អង្គហេតុដែលបញ្ជាក់ថាខ្លួន និងកូនសុំបានបំពេញតាមគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវ
- អង្គហេតុដែលបញ្ជាក់ថាឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនកូនសុំបានយល់ ព្រមចំពោះការបង្កើតសុំកូនពេញលេញ
- អង្គហេតុដែលបញ្ជាក់ថា មានស្ថានភាពចាំបាច់ពិសេស ក្នុងការបង្កើតកូនពេញលេញដើម្បីជាផលប្រយោជន៍របស់កូនសុំជាដើម។ល។

### ៣.៤. ការពិនិត្យពាក្យសុំ

ពេលទទួលបានពាក្យសុំ តុលាការត្រូវពិនិត្យពាក្យសុំថា បានសរសេរនូវចំណុចដែលច្បាប់តម្រូវហើយ ឬនៅ បើមិនទាន់សរសេរ ឬសរសេរមិនត្រឹមត្រូវ តុលាការត្រូវបង្គាប់ឱ្យភាគីអ្នកដាក់ពាក្យសុំកែតម្រូវពាក្យសុំ ដោយទុករយៈពេលកំណត់មួយសមរម្យ។ បើអ្នកដាក់ពាក្យសុំមិនព្រមកែតម្រូវតាមការបង្គាប់របស់តុលាការ តុលាការត្រូវលើកពាក្យសុំចោលដោយដីកាសម្រេច។ អ្នកដាក់ពាក្យសុំមានសិទ្ធិប្ដឹងជំទាស់លើដីកាសម្រេច លើកចោល

[24] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៨។
[25] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១១។

ពាក្យសុំ ក្នុងអំឡុងពេលដែលច្បាប់បានកំណត់[26]។ បន្ថែមពីនេះនៅពេលដាក់ពាក្យសុំ អ្នកដាក់ពាក្យ សុំត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល[27]។ ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យបង់ពន្ធនោះ។

### ៣.៥. ស្ថាប័នទទួលពាក្យសុំ

ដូចដែលយើងបានរៀបរាប់ និងបង្ហាញខ្លះៗពីចំណុចខាងលើថា ពាក្យសុំដែលធ្វើដោយអ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំនេះត្រូវយកទៅដាក់នៅតុលាការ ដើម្បីឱ្យតុលាការធ្វើការវិនិច្ឆ័យ និងចេញសេចក្ដីសម្រេចពីការបង្កើតសុំកូនពេញលេញ[28]។ ប៉ុន្តែសំនួរសួរថាតើអ្នកដាក់ពាក្យសុំនោះត្រូវយកពាក្យសុំ ទៅដាក់នៅតុលាការមួយណា? នៅឯណា?

ដោយយោងតាមតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង បានចែងថាតុលាការដែលមានសមត្ថកិច្ចនៅក្នុងការសម្រេចពីការបង្កើតសុំកូនពេញលេញនេះ គឺតុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម[29]។

- **ការចេញដីកាសម្រេច**

យោងតាមមាត្រា១០០៧ នៃក្រមរដ្ឋប្បវេណី ដើម្បីចេញសេចក្ដីសម្រេចចាប់ផ្ដើមពីរបបសុំកូន តុលាការត្រូវធ្វើការវិនិច្ឆ័យអំពី[30]៖ (១) ឆន្ទៈព្រមព្រៀងរវាងសហព័ន្ធជាឪពុកម្ដាយចិញ្ចឹម (២) អាយុរបស់កូនសុំ និងឪពុកម្ដាយចិញ្ចឹម (៣) ការឯកភាពរបស់ឪពុកម្ដាយបង្កើត និង (៤) លទ្ធភាពដែលអាចធ្វើឱ្យកុមារមានការថែទាំប្រសើរជាងមុន។

ដើម្បីអាចចេញដីកាសម្រេចចាប់ផ្ដើមសុំកូន ចាំបាច់ឆ្លងកាត់ការចិញ្ចឹមសាកល្បង (មាត្រា១០១៣)។ ប៉ុន្តែប្រសិនបើអ្នកដាក់ពាក្យសុំ បានធ្វើការចិញ្ចឹមកូនមុនពេលដាក់ពាក្យសុំកន្លងមក ហើយបើយល់ឃើញថាគ្មានភាពចាំបាច់ក្នុងការចិញ្ចឹមសាកល្បងទេ តុលាការអាចចេញដីកាសម្រេចចាប់ផ្ដើម របបសុំកូនដោយសរសេរបន្ថែមត្រង់ផ្នែកសំអាងហេតុថាអ្នកដាក់ពាក្យសុំបានចិញ្ចឹមកូនសុំពេលកន្លងមកហើយ តុលាការទទួលស្គាល់ការចិញ្ចឹមនេះ។

ក្នុងករណីដែលឪពុកម្ដាយចិញ្ចឹមមានបំណងដកពាក្យសុំ មុនពេលដែលតុលាការចេញសម្រេចក្ដីសម្រេចការធ្វើនេះអាចត្រូវបានអនុញ្ញាត ដោយសារមូលហេតុ បុគ្គលដែលបានដាក់ពាក្យសុំ បាត់បង់ឆន្ទៈក្នុងការ

---

[26] ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[27] ដដែល។

[28] ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, តារាងឧបសម្ព័ន្ធ។

[29] ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, តារាងឧបសម្ព័ន្ធ ចំណុចទី៧ នៃផ្នែកទី៤។

[30] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៧។

ស្មុំកូនពេញលេញ។ ប៉ុន្តែបើការធ្វើនេះ នៅក្រោយពេលតុលាការចេញដីកាសម្រេច ពោលគឺអំឡុងពេលបណ្តឹងជំទាស់ ជាចំណុចដែលចាំបាច់ត្រូវធ្វើការបកស្រាយ ព្រោះច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងពុំបានចែងពីបញ្ហានេះ[31]។ តាមច្បាប់ស្តីពីនីតិវិធីទាក់ទងនឹងទំនាក់ទំនងគ្រួសាររបស់ប្រទេសជប៉ុនមានតែដីការសម្រេចច្រានចោលពាក្យសុំទេ ដែលភាគីដាក់ពាក្យសុំអាចប្តឹងជំទាស់។ បន្ថែមពីនេះទៀត មាត្រា៨២ នៃច្បាប់ដដែលបានសម្តែងថា៖ « លើកលែងតែមានបទប្បញ្ញត្តិពិសេសចែងពី ផ្ទុយពីនេះអ្នកដាក់ពាក្យសុំអាចដកពាក្យសុំមួយផ្នែក ឬទាំងមូល មុនពេលតុលាការចេញដីកា សម្រេចលើពាក្យសុំ។[32] »។

យោងតាមគោលគំនិតនៃមាត្រានេះ រាល់ការដកពាក្យសុំ ក្រោយពេល តុលាការចេញដីកាសម្រេចចាប់ផ្តើមស្មុំកូនពេញលេញ មិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ។ ដោយឡែក ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងរបស់កម្ពុជាវិញ ការដកពាក្យបណ្តឹង និងបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចច្រានចោលពាក្យសុំ ពុំមានចែងទេ ហើយវាអាស្រ័យលើការបកស្រាយរបស់ភាគីកម្ពុជាចំពោះបញ្ហាខាងលើនេះ។

### ៣.៦. អំឡុងពេលសាកល្បងចិញ្ចឹម

ដោយសាររបបស្មុំកូនពេញលេញ បង្កើតឡើងដើម្បីផ្តល់គ្រួសារថ្មីដ៏កក់ក្តៅដល់កុមារ វាមានលក្ខខណ្ឌតឹងរឹង ដែលចាំចាច់ឱ្យតុលាការគិតពិចារណាអំពីឪពុកម្តាយចិញ្ចឹមនោះលទ្ធភាពក្នុងការចិញ្ចឹមកូនសុំនោះដែរឬទេ តើគោលបំណងស្មុំកូននោះ យកទៅដើម្បីជាប្រយោជន៍ផ្ទាល់របស់ឪពុកម្តាយចិញ្ចឹម ឬដើម្បីអនាគតកុមារទទួលបានការមើលថែដោយយកចិត្តទុកដាក់ដែរឬទេ តើពួកគេអាចរស់នៅចុះសម្រុងជាគ្នាឬអត់ ហេតុផលទាំងអស់នេះហើយ ដែលតុលាការអាចពិចារណាទៅលើភាពស័ក្តិសមរបស់ឪពុកម្តាយចិញ្ចឹមនោះ មុនពេលសម្រេចសេចក្តីជាស្ថាពរអំពីការបង្កើតរបបស្មុំកូនពេញលេញ ដោយទុកអំឡុងពេលសមរម្យដើម្បីអនុញ្ញាតឱ្យឪពុកម្តាយចិញ្ចឹមនោះយកកុមារដែលជាកូនសុំទៅរស់នៅជាមួយគ្នាដូចជាគ្រួសារតែម្តង[33]។

អំឡុងពេលសាកល្បងនឹងចាប់ផ្តើមអនុវត្ត ក្រោយពេលអ្នកសុំបានដាក់ពាក្យសុំបង្កើតសុំកូនទៅតុលាការ ជាគោលការណ៍ យ៉ាងតិច៦ (ប្រាំមួយ) ខែ ឬអាចលើសពីនេះ បើតុលាការយល់ឃើញថាគួរបន្ថែម[34]។ ប៉ុន្តែក្នុងករណីដែលកុមារនៃស្មុំកូននេះ ត្រូវបានរស់នៅជាមួយឪពុកម្តាយចិញ្ចឹមមុនពេលដាក់ពាក្យស្នើសុំមក ហើយនោះតុលាការមានឆន្ទានុសិទ្ធិក្នុងការបន្ថយរយៈពេលសាកល្បងចិញ្ចឹម ឬមិនចាំបាច់ទុករយៈពេលសាកល្បងនោះទេ។ ដូច្នេះ ដើម្បីធានាការបង្កើតរបបស្មុំកូនពេញលេញផ្តល់អត្ថប្រយោជន៍ដល់កុមារនោះ រយៈពេល

[31] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។
[32] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៨២។
[33] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៣។
[34] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៣។

សាកល្បងចិញ្ចឹមចាំបាច់ខ្លាំងណាស់ សម្រាប់តុលាការអាចវិនិច្ឆ័យយ៉ាងម៉ត់ហ្មត់ ដើម្បីជៀសផុតពីការរំលោភបំពាននានា ដែលអាចឱ្យតុលាការបញ្ឈប់ការបង្កើតសុំកូនពេញលេញវិញបាន[35]។

**ឧទាហរណ៍៖** កូនសុំធ្លាប់បានរស់នៅជាមួយនឹងឪពុកម្តាយចិញ្ចឹមជាយូរណាស់មកហើយ តាំងពីមុនពេលដាក់ពាក្យសុំបង្កើតសុំកូនពេញលេញទៅទៀត។ ក្នុងករណីយ៉ាងនេះ តុលាការអាចកំណត់រយៈពេលសាកល្បងខ្លីជាង ៦ខែ ឬមិនកំណត់រយៈពេលសាកល្បងតែម្តងក៏បានដែរ។

ដូច្នេះ ប្រសិនបើតុលាការយល់ឃើញថា នៅក្នុងអំឡុងពេលសាកល្បងនេះ កុមារមិនអាចរស់នៅចុះសម្រុងជាមួយនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមទេ ភាគច្រើនតុលាការនឹងមិនសម្រេចឱ្យបង្កើតសុំកូនពេញលេញទេ ពីព្រោះថាការធ្វើបែបនេះអាចនឹងធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្ត ក៏ដូចជាផលប្រយោជន៍របស់កុមារនាពេលអនាគត។

## ៣.៧. អានុភាពនៃសុំកូនពេញលេញ

យើងសង្កេតឃើញថា របបសុំកូនត្រូវបានកើតឡើង និងមានអានុភាពនៅពេលដីកាសម្រេចសុំកូនចូលជាស្ថាពរ។ ហើយនៅពេលចូលជាស្ថាពរនៃដីកាសម្រេចនេះ វាក៏បានបង្កើតនូវអានុភាពគតិយុត្តមួយចំនួនផងដែរ មានដូចជាអានុភាពទំនាក់ទំនងចំពោះកូនសុំ ឪពុកម្តាយចិញ្ចឹម ញាតិរបស់ឪពុកម្តាយចិញ្ចឹម និងបញ្ចប់ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតញាតិរបស់ឪពុកម្តាយបង្កើត[36]។

### ៣.៧.១. អានុភាពចំពោះកូនសុំ

- **ពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ៖** មានន័យថា នៅពេលដែលដីកាសម្រេចចូលជាស្ថាពររួចហើយ តាមការកំណត់របស់ច្បាប់នាំឱ្យទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និងកូនបង្កើត ត្រូវកាត់ផ្តាច់ទាំងស្រុង រួមទាំងទំនាក់ទំនងរវាងញាតិរបស់ឪពុកម្តាយបង្កើត និងកូនបង្កើតនោះត្រូវរលត់។ ដូចនេះ សុំកូនពេញលេញ និងឪពុកម្តាយបង្កើតលែងមានទំនាក់ទំនងញាតិភាព និងសន្តតិកម្មទៀតដែរ។ តែទោះជាយ៉ាងណាក៏ដោយ ច្បាប់បានទុកសិទ្ធិឱ្យមានទំនាក់ទំនងញាតិភាពបន្ត នៅក្នុងករណីដែលភាគីសហព័ទ្ធម្ខាងបានសុំកូនបង្កើតរបស់ភាគីសហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ ជាហេតុនាំឱ្យទំនាក់ទំនងឪពុកឬម្តាយបង្កើត និងញាតិសាច់លោហិតរបស់កូនសុំនោះនៅមានអត្ថិភាពដដែលដោយមិនត្រូវកាត់ផ្តាច់ឡើយ។
- **ពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ៖** បន្ទាប់ពីដីកាសម្រេចចូលជាស្ថាពរ អត្ថិភាពរបស់កូនសុំពេញលេញអាចទទួលបានសន្តតិកម្ម ពីឪពុកម្តាយចិញ្ចឹមដូចនឹងកូនបង្កើតដែរ ដោយឈរនៅលំដាប់សន្តតិជនទី១ និងមានសិទ្ធិទទួលនូវអាហារកាតព្វកិច្ចថែមទៀតផង។

[35] ដដែល។

[36] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៥។

### ៣.៧.២. អានុភាពចំពោះឪពុកម្តាយបង្កើត

- **ពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ៖** ក្រោយពេលដែលដីកាសម្រេចចូលជាស្ថាពរ ទំនាក់ទំនងឋានៈបុគ្គលរវាងឪពុកម្តាយបង្កើត ទំនាក់ទំនងរវាងញាតិរបស់ឪពុកម្តាយបង្កើត និងកូនបង្កើតត្រូវរលត់ទាំងស្រុង។ តែផ្ទុយមកវិញ បើភាគីសហព័ទ្ធម្ខាងបានសុំកូនបង្កើតរបស់ភាគីសហព័ទ្ធម្ខាងទៀត មកធ្វើជាកូនសុំ ជាហេតុនាំឱ្យទំនាក់ទំនងឪពុកឬម្តាយបង្កើត និងញាតិសាច់លោហិតរបស់កូនសុំនោះនៅបន្តអត្ថិភាពដដែល[37]។
- **ពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ៖** ក្រោយពីបញ្ចប់នូវទំនាក់ទំនងញាតិឪពុកម្តាយបង្កើត និងកូន នាំឱ្យកូនបាត់បង់នូវសិទ្ធិទទួលបានសន្តតិកម្ម ពីឪពុកម្តាយបង្កើត លែងជាសន្តតិជន លើសពីនេះ សិទ្ធិទទួលបានសន្តតិកម្មពីញាតិឪពុកម្តាយបង្កើតក៏ត្រូវបានរលត់ដែរ[38]។

### ៣.៧.៣. អានុភាពចំពោះឪពុកម្តាយចិញ្ចឹម

- **ពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ៖** តាមការសម្រេចរបស់តុលាការ ទំនាក់ទំនងឋានៈឪពុកម្តាយចិញ្ចឹម ដែលមានសិទ្ធិអំណាចមេបា និងកាតព្វកិច្ចចិញ្ចឹមបីបាច់កូនសុំត្រូវបានកើតឡើង លើសពីនេះទៀតទំនាក់ទំនងញាតិភាពរបស់ឪពុកម្តាយចិញ្ចឹម នឹងកូនសុំក៏ត្រូវបានកើតឡើងដែរ ដោយកូនសុំមានឋានៈដូចគ្នានឹងកូនបង្កើតគឺត្រូវទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម ហើយកូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម និងបញ្ចូលឈ្មោះក្នុងបញ្ជីគ្រួសារថ្មី និងបង្កើតសំបុត្រកំណើតតាមរយៈមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅរបស់ឪពុកម្តាយចិញ្ចឹមឬអាចប្រើនាមត្រកូលរបស់ខ្លួនមុនបាន[39]។

  ម្យ៉ាងវិញទៀត ក្នុងករណីដែលឪពុកម្តាយចិញ្ចឹមត្រូវបានលែងលះ អានុភាពឪពុកម្តាយចិញ្ចឹមនៅតែមានបន្តចំពោះកូនសុំនោះ ដោយការពិភាក្សារបស់ឪពុកម្តាយចិញ្ចឹម តើភាគីណាជាអ្នកមានសិទ្ធិអំណាចមេបា[40]។
- **ពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ៖** ទំនាក់ទំនងញាតិឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹមត្រូវបានកើតឡើងដែលឪពុកម្តាយចិញ្ចឹមមានសិទ្ធិផ្តល់សន្តតិកម្មឱ្យកូនសុំពេញលេញបាន ហើយសន្តតិជនត្រូវបានកើតឡើងនៅពេលនោះ។

---

[37] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៥ កថាខណ្ឌទី៣។

[38] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៤។

[39] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៥ កថាខណ្ឌទី១និងទី២។

[40] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៥ កថាខណ្ឌទី៣។

## ផ្នែកទី៤៖ ការកាត់កាល់សុំកូនពេញលេញ

**ការកាត់កាល់កូនសុំពេញលេញ** គឺជាការបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំ នឹងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម។ ការស្នើសុំកាត់កាល់កូនសុំពេញលេញបាន លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចដែលកំណត់នៅក្នុងមាត្រា១០១៦ នៃក្រមរដ្ឋប្បវេណី[41]។

### ៤.១. លក្ខខណ្ឌនៃការកាត់កាល់

ដោយការកាត់កាល់កូនសុំពេញលេញ ត្រូវធ្វើឡើងតាមផ្លូវតុលាការ ដោយបណ្តឹងទាមទារឱ្យកាត់កាល់ ហើយសម្រេចអំពីការកាត់កាល់ ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ហើយអ្នកដែលមានសិទ្ធិប្តឹងនឹងការកាត់កាល់សុំកូនពេញលេញបាន គឺមានតំណាងអយ្យការ ឪពុកម្តាយបង្កើត និងភាគីកូនសុំ[42]។

#### ៤.១.១. តំណាងអយ្យការ

តុលាការជាអ្នកមានអំណាចសម្រេច ពីការកាត់កាល់ភាគីនៃកូនសុំបាន ប្រសិនបើឃើញថាការកាត់កាល់នេះ ពិតជាមានភាពមិនបម្រើផលប្រយោជន៍របស់កូនសុំតាមពាក្យរបស់កូនសុំ។

#### ៤.១.២. ឪពុកម្តាយបង្កើត

បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផលផ្សេងៗ ដែលបំពានផលប្រយោជន៍កូនសុំយ៉ាងធ្ងន់ធ្ងរ ហើយឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

#### ៤.១.៣. កូនសុំ

ប្រសិនបើឪពុកម្តាយចិញ្ចឹម មិនអាចមើលថែរក្សាកូនសុំឱ្យសមស្របទៅតាមការស្នើសុំនោះ ភាគីកូនសុំអាចធ្វើការប្តឹង និងកាត់កាល់សុំកូនពេញលេញបាន ដោយផ្អែកទៅតាមមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី ធ្វើបែបនេះ គឺដើម្បីការពារនូវផលប្រយោជន៍នៃកូនចិញ្ចឹម[43]។

ការកាត់កាល់ត្រូវធ្វើឡើងតាមនីតិវិធីបណ្តឹងឋានៈបុគ្គល ហើយតុលាការធ្វើការសម្រេចសេចក្តីដោយចេញសាលក្រម។

### ៤.២. មូលហេតុនៃការកាត់កាល់

ទោះបីកូនសុំមិនមែនជាកូនបង្កើតក៏ពិតមែន ប៉ុន្តែក្នុងច្បាប់បានកំណត់យ៉ាងច្បាស់លាស់ពីសិទ្ធិនិងករណីយកិច្ចដែលកូនសុំទទួលបានបន្ទាប់ពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ហេតុនេះកូនសុំមានលក្ខណៈដូចនឹងកូនបង្កើតដែរ ដូច្នេះឪពុកម្តាយចិញ្ចឹម និងកូនសុំក៏មិនអាចបញ្ចប់ទំនាក់ទំនងនឹងគ្នាដោយ

[41] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៦។

[42] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៦ កថាខណ្ឌទី១។

[43] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៧។

ងាយៗនោះទេ។ ម៉្យាងវិញទៀត សុំកូនគ្រាន់តែជាកូនដែលសន្មតតាមច្បាប់ នៅតែមិនមែនជាកូនបង្កើតដែលកើតចេញមកតាមខ្សែលោហិត ដូចនេះសុំកូនអាចបញ្ចប់ទៅវិញដោយការកាត់កាល់ ដែលមានលក្ខខណ្ឌចែងដោយតឹងរឹងនៅក្នុងមាត្រា១០១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧[44]។

សុំកូនកើតឡើង ដោយសារតែចង់ជួយសង្គ្រោះកុមារឱ្យទទួលបានគ្រួសារថ្មីដែលមានសុភមង្គលពេញលេញពោរពេញទៅដោយការរស់នៅដោយសមរម្យ ប៉ុន្តែប្រសិនបើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផលផ្សេងៗទៀតដែលបំពានដល់ផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ឬ មិនទទួលបាននូវការចិញ្ចឹមបីបាច់ថែរក្សាយ៉ាងត្រឹមត្រូវពីឪពុកម្តាយចិញ្ចឹមនោះ កូនសុំអាចធ្វើពាក្យបណ្តឹងទាមទារនៃការកាត់កាល់បាន។

ក្រៅពីនេះក៏នៅមានករណីមួយទៀតដែលជាមូលហេតុនៃការកាត់កាល់នេះ គឺប្រសិនបើឪពុកម្តាយបង្កើតមានលទ្ធភាពគ្រប់គ្រាន់ក្នុងការថែរក្សាកូនបានឡើងវិញ។ លើសពីនេះក៏នៅមានចំណុចមួយចំនួនផ្សេងទៀតដែលជាមូលហេតុនៃបណ្តឹងទាមទារនៃការកាត់កាល់ផងដែរ គឺអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់តុលាការ។

### ៤.៣. អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

តាមក្រមរដ្ឋប្បវេណីកម្ពុជា ទទួលស្គាល់នូវការបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត និងញាតិភាពនៃឪពុកម្តាយបង្កើត និងកូនសុំក្រោយពីបញ្ចប់ដោយសុំកូនពេញលេញត្រូវកើតឡើងវិញចាប់ពីថ្ងៃបានកាត់កាល់។ រីឯញាតិភាពរវាងកូនចិញ្ចឹមសហព័ទ្ធរបស់កូននោះ បច្ឆាញាតិផ្ទាល់ និងសហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះត្រូវបានបញ្ចប់ដោយការកាត់កាល់ ឬ លែងទទួលស្គាល់។

សរុបសេចក្តីមក អានុភាពនៃសាលក្រមសម្រេចកាត់កាល់សុំកូនពេញលេញ នឹងធ្វើឱ្យកាត់ផ្តាច់ទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹមនឹងកូនសុំ និងបានបង្កើតឡើងវិញនូវទំនាក់ទំនងញាតិជាមួយឪពុកម្តាយបង្កើត[45]។

### ៤.៤. សិទ្ធិរបស់កូនសុំពេញលេញ

#### ៤.៤.១. សិទ្ធិទទួលដឹងពីកំណើត

ទោះបីជាយើងធ្វើការបកស្រាយខាងលើថា ការសុំកូនពេញលេញជាការសុំកូនតាមផ្លូវច្បាប់ ដោយធ្វើឡើងតាមលំហូរនីតិវិធីច្បាប់ ហើយការសុំកូននេះតម្រូវឱ្យកូនសុំផ្តាច់ទំនាក់ទំនងញាតិភាពពីឪពុកម្តាយបង្កើត និងញាតិលោហិតរបស់ឪពុកម្តាយបង្កើត។

---

44 ដដែល។

45 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៧។

ប៉ុន្តែកូនសុំនោះនៅតែមានសិទ្ធិដឹងពីកំណើតរបស់ខ្លួនជានិច្ច នៅពេលដែលខ្លួនបានក្លាយជានីតិជន ព្រោះថានៅពេលដែលមានការសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ប៉ុន្តែនៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនបានសរសេរចំណុចស្តីពីសុំកូនឡើយ។

ដោយយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងថា កូនសុំពេញលេញដែលបានក្លាយជានីតិជនអាចទាមទារឱ្យបង្ហាញព័ត៌មានក្នុងទំហំដែលចាំបាច់ចំពោះតុលាការដែលរក្សាទុកសំណុំរឿងស្តីពីសុំកូនបាន។ ប៉ុន្តែ ក្នុងករណីដែលកូនសុំនោះមានបំណងទុច្ចរិត គេអាចបដិសេធមិនធ្វើតាមការទាមទារសុំនោះបាន[46]។

**៤.៤.២. សិទ្ធិប្រាស់នាមត្រកូលដែលពេញចិត្ត**

នៅពេលកូនសុំមានអានុភាព កូនសុំនឹងក្លាយជាកូនពេញសិទ្ធិរបស់ឪពុកម្តាយចិញ្ចឹមនោះ ហើយមានឋានៈដូចកូនបង្កើតដែរ[47]។ នៅក្នុងការប្រើប្រាស់នាមត្រកូលវិញ យើងឃើញថាកូនៗភាគច្រើនយកនាមត្រកូលតាមឪពុកម្តាយ ហើយការដាក់នាមត្រកូលរបស់កូន ជាទូទៅធ្វើឡើងតាំងពីថ្ងៃដែលកូននោះទើបតែកើតមកម្ល៉េះ។ ដូច្នេះយើងអាចទាញពន្យល់បានថា កូនសុំនោះប្រាកដជាមាននាមត្រកូលរបស់ខ្លួនមុនពេលបង្កើតសុំកូនទៅទៀត។ ដូច្នេះទើបបន្ទាប់ពីការបង្កើតសុំកូនរួច គេអាចផ្តល់ជម្រើសដល់កូនសុំនោះ ក្នុងការប្រើប្រាស់នាមត្រកូលថ្មីរបស់ឪពុកម្តាយចិញ្ចឹម ឬ ប្រើប្រាស់នាមត្រកូលនៅមុនពេលសុំកូនរបស់ខ្លួនបាន[48]។

ប៉ុន្តែ ក្នុងករណីដែលកូននោះជាកូនដែលគេរើសបាន ហើយគ្មាននាមត្រកូល នៅពេលបង្កើតសុំកូន កូននោះត្រូវប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមជាដាច់ខាត។

**៤.៤.៣. សិទ្ធិស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្តាយ**

អំណាចមេបាជាសិទ្ធិ និងករណីយកិច្ចក្នុងការបីបាច់ថែរក្សាកូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ[49]។

ជាទូទៅ កូនគ្រប់រូបដែលជាអនីតិជនត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងថែរក្សារបស់ឪពុកម្តាយ ឬ អ្នកមានអំណាចមេបាររបស់កូននោះតាមផ្លូវច្បាប់។ ដោយឡែក ចំពោះករណីកូនសុំវិញ នៅពេលដែលមានការសុំកូនពេញលេញមានអានុភាពហើយនោះ កូនសុំនឹងត្រូវបញ្ចប់ញាតិភាពរវាងខ្លួន និងឪពុកម្តាយបង្កើត ហើយបង្កើតញាតិភាពថ្មីជាមួយឪពុកម្តាយចិញ្ចឹមវិញ។ដូច្នេះកូនសុំមិនត្រូវស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្តាយបង្កើតទៀតទេ។ កូនសុំដែលនៅតែជាអនីតិជនត្រូវស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្តាយចិញ្ចឹមវិញ។

[46] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៩ កថាខណ្ឌទី១។

[47] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០ កថាខណ្ឌទី១។

[48] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០ កថាខណ្ឌទី២។

[49] *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ២០៣។

យ៉ាងណាមិញ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាងក្លាយឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបាររួមរបស់ឪពុកបង្កើត ឬម្តាយបង្កើត និងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម។

### ៤.៤.៤. សិទ្ធិទទួលបានអាហារកាតព្វកិច្ច

ពាក្យថា « **អាហារកាតព្វកិច្ច** » ដោយយោងតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណីបានឱ្យនិយមន័យថា ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិជាមួយគ្នា[50]។

ដូច្នេះ មានន័យថាកូនគ្រប់រូបទោះជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវតែទទួលបានការផ្គត់ផ្គង់ពីឪពុកម្តាយតាមរយៈប្រាក់ ឬទ្រព្យសម្បត្តិនានា សម្រាប់ការរស់នៅប្រចាំថ្ងៃ និងការសិក្សារៀនសូត្រជាដើម។

### ៤.៤.៥. សិទ្ធិធ្វើនិងទទួលសន្តតិកម្ម

ការធ្វើសន្តតិកម្ម គឺជាការផ្ទេរសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់ (សន្ទានុក្រមផ្នែករដ្ឋប្បវេណី)។ ក្រោយពីបង្កើតសុំកូនពេញលេញកូនសុំទទួលបានសិទ្ធិដូចកូនបង្កើត ហើយក្នុងនោះក៏មានសិទ្ធិធ្វើ និងទទួលសន្តតិកម្មដែរ។ ដូច្នេះកូនសុំ និងឪពុកម្តាយចិញ្ចឹមមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមក ហើយញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមក៏អាចមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមកនឹងកូនសុំបានដែរ[51]។

តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនលំដាប់ទី១ជានិច្ច។ ជារួម គឺកូនៗរបស់មតកជនមានសិទ្ធិក្លាយជាសន្តតិជនលំដាប់ទី១ជានិច្ច បើពុំមានបញ្ហាអ្វីកើតឡើង។ ការបែងចែកមរតករបស់មតកជនចំពោះសន្តតជនលំដាប់ទី១ ពោលគឺកូនៗនេះត្រូវចែកឱ្យមានចំណែកស្មើៗគ្នាគ្រប់រូបទោះបីជាកូននោះជាកូនបង្កើតក្តី ឬកូនសុំក្តី[52]។

### ៤.៤.៦. សិទ្ធិប្តឹងទាមទារមរតក

ជាទូទៅ ដូចយើងបានធ្វើការបញ្ជាក់នៅខាងលើថាកូនៗទាំងអស់ មិនថាកូនបង្កើត ឬកូនសុំទេ សុទ្ធតែត្រូវក្លាយជាសន្តតិជនលំដាប់ទី១។ ដូច្នេះមានន័យថា កូនៗមានសិទ្ធិទទួលបានមរតកពីមតកជនជានិច្ច បើខ្លួនពុំត្រូវបានកាត់កាល់ ឬក្លាយអភ័ព្វបុគ្គលទេ។

---

[50] *សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ២០២។

[51] *សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ១៤៥។

[52] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៦ កថាខណ្ឌទី២។

ប៉ុន្តែបើក្នុងករណីដែលកូនណាមួយ ពុំទទួលបានមរតកពីមតកជន ទាំងដែលខ្លួនគ្មានកំហុសអ្វីនោះ កូននោះអាចមានសិទ្ធិប្ដឹងទាមទារ ដើម្បីទទួលបានចំណែកមរតកដែលជារបស់ខ្លួន។ នៅក្នុងករណីនេះ ចំណែកមរតកត្រូវចែកស្មើៗគ្នា ទោះជាកូននោះជានីតិជន ឬអនីតិជន ជាកូនបង្កើតឬ កូនសុំក៏ដោយ។

➢ **កំណត់ចំណាំ៖**

**ការចុះបញ្ជីនៃសុំកូនពេញលេញ និងការរក្សាការសម្ងាត់៖** សុំកូនពេញលេញ គឺជាមធ្យោបាយសង្គ្រោះក្មេងអភ័ព្វ ហេតុនេះការបង្ហាញអង្គហេតុសុំកូន អាចជាបច្ច័យអាក្រក់សម្រាប់ជីវភាពឯកជន និងការលូតលាស់របស់កុមារ ដូចនេះ បញ្ជីអត្រានុកូលដ្ឋាន និងសំបុត្រកំណើតថ្មីរបស់កូនសុំដែលធ្វើឡើងដោយការបង្កើតសុំកូនពេញលេញ មិនត្រូវសរសេរអំពីឈ្មោះ របស់ឪពុកម្ដាយបង្កើត ឬចំណុចសួរកូនសុំឡើយ ហើយត្រូវចុះឈ្មោះ ឪពុកម្ដាយចិញ្ចឹម គឺជាឪពុកម្ដាយបង្កើត។

**សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំពេញលេញ៖** កូនសុំពេញលេញ ដែលក្លាយខ្លួនទៅជានីតជនអាចទាមទារឱ្យបង្ហាញព័ត៌មានក្នុងទំហំចាំបាច់ចំពោះតុលាការដែលភទុកសំណុំរឿងស្ដីពីសុំកូននេះ តាមរយៈពាក្យសុំលើកលែងតែ មានគោលបំណងមិនត្រឹមត្រូវចំពោះការរក្សាទុកសំណុំរឿង និងវិធីទាមទារឱ្យបង្ហាញជាអាទិ៍។

# ជំពូកទី ៣
# ស្មុំកូនធម្មតា

# ជំពូកទី ៣

# ស្មុំកូនធម្មតា

នៅក្នុងសង្គមរស់នៅសព្វថ្ងៃគ្រួសារ គឺជាកោសិការបស់សង្គមដ៏សំខាន់ ព្រោះបើគ្មានគ្រួសារចំនួនប្រជាជន និងសេដ្ឋកិច្ចរបស់ប្រទេសជាតិនោះ ក៏មិនអាចរីកចម្រើន និងរីកលូតលាស់បានឆាប់រហ័សដែរ ដូច្នេះ កត្តាមនុស្ស ពិតជាមានសារសំខាន់ ក៏ដូចការរក្សាការពារ និងជាអត្តសញ្ញាណរបស់ប្រជាជាតិនៅលើឆាកអន្តរជាតិ។ ជាការពិតណាស់ គ្រួសារខ្លះពុំអាចមានលទ្ធភាពមានកូន ហើយកុមារខ្លះត្រូវបានឪពុកម្តាយបោះចោល ឬគ្មានលទ្ធភាពចិញ្ចឹម ព្រោះដើម្បីចិញ្ចឹមមនុស្សម្នាក់វាមិនមែនរឿងងាយស្រួលទេ តម្រូវឱ្យគ្រួសារនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអប់រំកុមារនោះក្លាយជាធនធានល្អនៅក្នុងសង្គម។ នៅក្នុងច្បាប់មានរបបមួយ គឺស្មុំកូនធម្មតាដែលសហព័ទ្ធមានគោលបំណងចង់បានកូនមកចិញ្ចឹមចាត់ទុកដូចជាកូនបង្កើតដែរ។

ស្មុំកូនធម្មតា សំដៅដល់ការសុំកូនដែលកូននោះអាចជាអនីតិជន ឬនីតិជនដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

ស្មុំកូនធម្មតា គឺជាការស្មុំកូនមួយប្រភេទដែលមានញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតនៅតែបន្តអត្ថិភាព មិនមានការកាត់ផ្តាច់ មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ហើយកូននិងឪពុកម្តាយបង្កើតមានសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។

លើសពីនេះ កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនស្មុំកូនបាន ហើយកូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម នឹងត្រូវបានទទួលសិទ្ធិ និងករណីយកិច្ចដូចគ្នា និងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម។

## ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃស្មុំកូនធម្មតា

ស្មុំកូនធម្មតា អាចហៅម្យ៉ាងទៀតបានថា ស្មុំកូនសាមញ្ញ គឺទម្រង់មួយដែលបានសម្រួលពីស្មុំកូនពេញលេញ។ របបដែលដាក់កូនសុំទៅក្នុងការគ្រប់គ្រង ទាំងស្រុងរបស់គ្រួសារឪពុកម្តាយចិញ្ចឹមហើយមិនមានការកាត់ផ្តាច់នូវចំណងទំនាក់ទំនងរវាងកូនសុំនិងឪពុកម្តាយបង្កើត។ ប្រព័ន្ធស្មុំកូនធម្មតានេះ ត្រូវបានបង្កើតឡើងដោយតម្រូវឱ្យមានការពាក់ព័ន្ធពីតុលាការ ដើម្បីបង្កើតអានុភាពញាតិលោហិតតាមផ្លូវច្បាប់ដូចជាសន្តតិកម្ម និងអាហារកិច្ចជាដើម។

### ១.១. និយមន័យ

ស្មុំកូនធម្មតា សំដៅដល់ការសុំកូនដែលកូននោះអាចជាអនីតិជន ឬនីតិជនដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

ស្មុំកូនធម្មតា សំដៅដល់ការសុំកូនដែលកូននោះអាចជាអនីតិជន ឬនីតិជនដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

ស្មុំកូនធម្មតា គឺជាការស្មុំកូនមួយប្រភេទដែលមានញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតនៅតែបន្ត អត្ថិភាព មិនមានការកាត់ផ្តាច់ មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ហើយកូន និងឪពុកម្តាយបង្កើតមានសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។

**១.២. លក្ខណៈពិសេសនៃស្មុំកូនធម្មតា**

ស្មុំកូនធម្មតាមិនមានលក្ខណៈតឹងរឹងដូចស្មុំកូនពេញលេញនោះទេ។ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាពរហូត ហើយកូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមកបាន។ កូនសុំនិងឪពុកម្តាយបង្កើតក៏មានសិទ្ធិទាមទារ និងមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចផងដែរ។ លើសពីនេះ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលបាននូវសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម។

**ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា**

លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា ក៏មិនខុសពីលក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញប៉ុន្មានដែរ មានដូចជា អាយុរបស់ឪពុកម្តាយចិញ្ចឹមនិងកូនសុំ ការចូលរួមរបស់សហព័ទ្ធម្ខាងរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយ ឬម្តាយចិញ្ចឹមក្នុងករណីបុគ្គលនោះមានសហព័ទ្ធ ការចូលរួមរបស់ឪពុកម្តាយបង្កើត និងមូលដ្ឋានវិនិច្ឆ័យដោយតុលាការ និងពិចារណា។

ដូច្នេះ ដើម្បីបង្កើតស្មុំកូនធម្មតាបានមានលក្ខខណ្ឌមួយចំនួនត្រូវតែបំពេញ ជាពិសេស គឺត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់តុលាការ។

**២.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតស្មុំកូនធម្មតា**

លក្ខខណ្ឌគ្រឹះនៃការបង្កើតស្មុំកូនធម្មតា មានលក្ខណៈមិនស្មុគស្មាញដូចការបង្កើតស្មុំកូនពេញលេញនោះទេ ពោលគឺច្បាប់មិនបានរឹតបន្តឹងខ្លាំងលើលក្ខខណ្ឌទាំងនេះទេ ព្រោះថាការបង្កើតស្មុំកូនធម្មតា គេបានផ្តល់សិទ្ធិអាទិភាពច្រើនឱ្យជនដែលនឹងក្លាយជាកូនសុំនោះផ្ទាល់ នៅក្នុងការសម្រេចចិត្តបង្កើតស្មុំកូនធម្មតានេះឡើង។ យ៉ាងណាមិញ យើងឃើញថាលក្ខខណ្ឌដែលគេបានកំណត់គឺសំដៅលើបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលនឹងក្លាយជាកូនស្មុំ។

**២.១.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម**

មានលក្ខណៈស្រដៀងគ្នានឹងការបង្កើតស្មុំកូនពេញលេញដែរ លក្ខខណ្ឌដែលច្បាប់បានកំណត់ចំពោះបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមគឺ លក្ខខណ្ឌអាយុ ការមាន ឬគ្មានសហព័ទ្ធ និងការយល់ព្រមពីសហព័ទ្ធ(បើមាន) ប៉ុន្តែនៅត្រង់លក្ខខណ្ឌនេះ ច្បាប់មិនបានកំណត់ថាទាល់តែជនដែលមានសហព័ទ្ធទើបអាចបង្កើតស្មុំកូនធម្មតាបាននោះទេ។

**ក. ការមានសហព័ទ្ធ និងការយល់ព្រមពីសហព័ទ្ធ**

ចំពោះការសុំកូនធម្មតា ក៏មិនខុសគ្នាប៉ុន្មានពីការសុំកូនពេញលេញដែរ។ ប៉ុន្តែការសុំកូនធម្មតា ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនបានកំណត់ឱ្យបានច្បាស់លាស់ថាជនដែលនឹងក្លាយជា ឪពុក ឬម្ដាយចិញ្ចឹម ត្រូវតែមានសហព័ទ្ធនោះទេ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថាជនដែលមានបំណងចង់បង្កើតសុំកូនធម្មតាអាចធ្វើទៅបាន ទោះបីជាខ្លួនមិនមានសហព័ទ្ធក៏ដោយ។ ប៉ុន្តែ ចំពោះជនដែលមានសហព័ទ្ធហើយចង់បង្កើតសុំកូនធម្មតាលើអនីតិជននោះនៅក្នុងការដាក់ពាក្យសុំបង្កើតសុំកូនធម្មតា ត្រូវតែធ្វើឡើងជាមួយសហព័ទ្ធម្ខាងទៀត[53] រួមជាមួយនឹងអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ។ ចំពោះការសុំកូនធម្មតាដែលជានីតិជនក្ដី ក៏ត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតដែរ[54]។ យ៉ាងណាមិញក្នុងករណីដែលគេយកកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ ឬករណីដែលសហព័ទ្ធម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួន នៅក្នុងការដាក់ពាក្យសុំបាននោះ សហព័ទ្ធម្ខាងដែលនឹងក្លាយជាឪពុក ឬម្ដាយចិញ្ចឹមរបស់កូននោះអាចដាក់ពាក្យសុំបានដោយមិនចាំបាច់ មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតឡើយ[55]។

**ខ. អាយុ**

ចំពោះអាយុរបស់ជនដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី២៥(ម្ភៃប្រាំ) ឆ្នាំឡើងទៅទើបអាចធ្វើការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាបាន[56]។ យើងឃើញថាច្បាប់មិនបានកំណត់ពីគម្លាតអាយុរវាងឪពុក ឬម្ដាយចិញ្ចឹមនិងកូនសុំឡើយ។ ទោះជាច្បាប់បានកំណត់ អំពីអាយុអប្បបរមាក៏ដោយ ក៏មិនបានកំណត់ពីអាយុអតិបរមារបស់ឪពុក ឬម្ដាយចិញ្ចឹមដែរ។ យ៉ាងណាមិញ តុលាការគួរតែធ្វើការវិនិច្ឆ័យឱ្យបានល្អិតល្អន់មុននឹងសម្រេចឱ្យមានការសុំកូននេះ ទោះបីជាការសុំកូនធម្មតាក្ដី ជៀសវាងភាពមិនប្រក្រតីណាមួយអាចកើតឡើង។ គួរគប្បីពិនិត្យមើលអាយុជនដែលនឹងក្លាយជាឪពុកឬម្ដាយចិញ្ចឹមមិនគួរឱ្យមានភាពប្រហែលគ្នា ឬស្មើគ្នានោះឡើយ។

[53] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២១ វាក្យខណ្ឌទី១។

[54] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២២ វាក្យខណ្ឌទី១។

[55] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២១ វាក្យខណ្ឌទី២។

[56] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០ វាក្យខណ្ឌទី១។

### ២.១.២. លក្ខខណ្ឌចំពោះកូនសុំធម្មតា

#### ក. អាយុ

ការសុំកូនធម្មតា មានលក្ខណៈផ្ទុយគ្នាពីការសុំកូនពេញលេញជាច្រើនចំណុចតួយ៉ាងលក្ខខណ្ឌអាយុរបស់កូនសុំនេះ។ នៅក្នុងការបង្កើតសុំកូនធម្មតា ច្បាប់មិនបានកំណត់ពីអាយុរបស់កូនសុំទេ មានន័យថាគេអាចធ្វើការបង្កើតសុំកូនធម្មតាលើក្មេងអាយុប៉ុន្មានក៏បានដែរ។ កូនសុំធម្មតាអាចជានីតិជន ឬអនីតិជន។ ក្នុងក្រមរដ្ឋប្បវេណីក៏ពុំបានចែងអំពីលក្ខខណ្ឌអាយុរបស់កូនសុំ តែបានចែងពីអាយុរបស់ជនដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីបានចែងដែរថា បុគ្គលដែលនឹងក្លាយជាកូនសុំមិនអាចមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានទេ[57]។

#### ខ. ទំនាក់ទំនងញាតិ

ចំពោះលក្ខខណ្ឌនេះ គេសំដៅលើទំនាក់ទំនងរវាងកូនសុំ និងបុគ្គលដែលជាឪពុកម្តាយចិញ្ចឹម។ តាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានទេ[58]។ ពាក្យថា « បុព្វញាតិ » តាមសទ្ទានុក្រមផ្នែករដ្ឋប្បវេណីមានន័យថា ជនដែលស្ថិតនៅក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន។ ដូច្នេះ ទំនាក់ទំនងរវាងកូនសុំនិងឪពុកម្តាយចិញ្ចឹមត្រូវតែជាអ្នកដែលមិនជាប់សាច់ឈាមអ្វីនឹងគ្នា លើកលែងតែករណីដែលសហព័ទ្ធម្ខាងសុំកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនចិញ្ចឹម។

## ផ្នែកទី៣ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា

### ៣.១. លក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា ក៏មិនខុសពីលក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញប៉ុន្មានដែរ មានដូចជា អាយុរបស់ឪពុកម្តាយចិញ្ចឹមនិងកូនសុំ ការចូលរួមរបស់សហព័ទ្ធម្ខាងរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយ ឬម្តាយចិញ្ចឹមក្នុងករណីបុគ្គលនោះមានសហព័ទ្ធ ការចូលរួមរបស់ឪពុកម្តាយបង្កើត និងមូលដ្ឋានវិនិច្ឆ័យដោយតុលាការ និងពិចារណា។

ដូច្នេះ ដើម្បីបង្កើតសុំកូនធម្មតាបានមានលក្ខខណ្ឌមួយចំនួនត្រូវតែបំពេញ ជាពិសេស គឺត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់តុលាការ។

---

[57] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[58] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

## ៣.២. លក្ខខណ្ឌទម្រង់នៃការបង្កើតស្មុំកូនធម្មតា

### ៣.២.១ .លក្ខខណ្ឌទម្រង់

មិនថាតែការស្មុំកូនពេញលេញទេដែលត្រូវឱ្យបំពេញតាមលក្ខខណ្ឌទម្រង់ ប៉ុន្តែការស្មុំកូនធម្មតាក៏ត្រូវបំពេញតាមលក្ខខណ្ឌទម្រង់ដែលច្បាប់បានកំណត់ដូចគ្នា។ លក្ខខណ្ឌទម្រង់គឺជា នីតិវិធីឬរបៀបនៃការដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាតាមផ្លូវតុលាការ ដើម្បីទទួលបានការវិនិច្ឆ័យ និងសេចក្តីសម្រេចពីតុលាការ។

### ក. ការដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតា

ចំពោះសហព័ទ្ធណាដែលចង់បានកូនអ្នកដទៃដែលមិនមែនជាសាច់ញាតិរបស់ខ្លួនមកចិញ្ចឹម ហើយអនុញ្ញាតឱ្យទំនាក់ទំនងសាច់ញាតិបង្កើតរបស់កូនស្មុំនៅតែបន្តអត្ថិភាពនោះ សហព័ទ្ធដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹម ត្រូវជាអ្នកដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាទៅតុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយជាកូនសុំនោះ។

ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំ គឺជាអនីតិជនត្រូវឱ្យអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំខាងលើនេះ (មាត្រា១០២០)[59]។ នៅក្នុងការវិនិច្ឆ័យសេចក្តីលើរឿងនេះ តុលាការធ្វើការសម្រេចសេចក្តីដោយចេញជាដីកាសម្រេច ផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

### ខ. លក្ខខណ្ឌទាក់ទងនឹងកូនសុំ

ដោយនៅក្នុងលក្ខខណ្ឌស្មុំកូនធម្មតាមិនបានកំណត់ជាដាច់ខាតឡើយពីអាយុនៃកូនសុំ ដូច្នេះ កូនសុំអាចជាអនីតិជន ឬនីតិជន ប៉ុន្តែចំណុចសំខាន់ គឺតម្រូវឱ្យ[60]៖

បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយបុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ[61]។

- **ករណីបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន**

តាមការកំណត់របស់ច្បាប់តុលាការអាចបង្កើតស្មុំកូនបាន លុះត្រាតែយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីប្រសិនបើបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកដែលត្រូវផ្តល់ការយល់ ព្រមទៅនឹងការបង្កើតសុំកូនធម្មតា គឺអ្នកតំណាងតាមច្បាប់កំណត់របស់អនីតិជន ពោលគឺ អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ហើយក្នុងករណីដែលបុគ្គល

---

[59] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០។

[60] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០ កថាខណ្ឌទី១។

[61] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២០ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

ដែលនឹងក្លាយជាកូនសុំជាអនីតិជន បើឪពុកម្តាយបង្កើតរបស់បុគ្គលនោះបានលែងលះគ្នាហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីស្ថានភាព ក៏ប៉ុន្តែប្រសិនបើអនីតិជននោះ បានដល់អាយុ ១៥ ឆ្នាំ ហើយត្រូវតែទទួលការបង្ហាញឆន្ទៈយល់ព្រមពីអនីតិជននោះផងដែរ ទើបអាចបង្កើតសុំកូនធម្មតាបាន[62]។

➢ **ករណីបុគ្គលដែលនឹងក្លាយជាកូនសុំជានីតិជន**

យ៉ាងណាមិញនៅក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំគឺជានីតិជន តុលាការនឹងសម្រេចឱ្យបង្កើតសុំកូនធម្មតា បើពិនិត្យឃើញថាមានឆន្ទៈពិតប្រាកដ ក្នុងការបង្កើតទំនាក់ ទំនងសុំកូនធម្មតាជាមួយនឹងឪពុកម្តាយចិញ្ចឹម។

**គ. លក្ខខណ្ឌទាក់ទងនឹងឪពុកម្តាយចិញ្ចឹម**

បុគ្គលដែលមានអាយុចាប់ពី២៥ ( ម្ភៃប្រាំឆ្នាំ ) ឡើងទៅអាចដាក់ពាក្យជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ។ ប៉ុន្តែបុគ្គលដែលនឹងក្លាយជាកូនសុំ មិនទៅជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬបុគ្គលដែលមានអាយុច្រើនជាងបុគ្គលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ។ ក្នុងករណីដែលបុគ្គលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវដាក់ពាក្យសុំដែលបានកំណត់ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងមាត្រា១០២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ទន្ទឹមនឹងនេះ បុគ្គលដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹម អាចជាបុគ្គលដែលមាន សហព័ទ្ធក៏បាន ឬជាបុគ្គលដែលមិនមានសហព័ទ្ធក៏បានដែរ។ ប្រសិនបើជាបុគ្គលដែលមានសហព័ទ្ធ គឺចាំបាច់ត្រូវតែមានការយល់ព្រមពីសំណាក់សហព័ទ្ធម្ខាងទៀតផង ទើបសហព័ទ្ធម្ខាង អាចដាក់ពាក្យសុំបង្កើតសុំកូនធម្មតាបាន។ ក៏ប៉ុន្តែ ប្រសិនបុគ្គលដែលមានសហព័ទ្ធ ហើយមានបំណងសុំកូនដែលជាអនីតិជន ពោលគឺតម្រូវឱ្យសហព័ទ្ធទាំងពីរនាក់ ដាក់ពាក្យសុំបង្កើតសុំកូនធម្មតាដោយសហការគ្នា ដើម្បីធានាសុវត្ថិភាពនិងការទំនុកបម្រុងកូនសុំនោះ។

ហើយប្រសិនបើសហព័ទ្ធម្ខាង មិនអាចបង្ហាញឆន្ទៈបាន ដូចជាករណីមានជម្ងឺផ្ទៃកស្មារតី ជាដើម ការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាអាចធ្វើឡើងដោយសហព័ទ្ធតែម្ខាងបាន។ ដូចគ្នាដែរ ប្រសិនបើជាការសុំបង្កើតសុំកូនធម្មតាជាមួយនឹងកូនជាអនីតិជនរបស់សហព័ទ្ធម្ខាងទៀត ការដាក់ពាក្យសុំនឹងត្រូវធ្វើដោយ សហព័ទ្ធតែម្ខាងប៉ុណ្ណោះ។

ក្រៅពីនេះទៀត បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវតែមានឆន្ទៈពិតប្រាកដ ក្នុងការបង្កើតទំនាក់ទំនងសុំកូន។ ក្នុងន័យនេះ បើតុលាការយល់ឃើញថា សុំកូនត្រូវបានបំពាន ក្នុងគោលបំណងរៀប

[62] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៤។

អាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទផ្សេងគ្នា ឬដូចគ្នា ឬក្នុងគោលបំណង មិនត្រឹមត្រូវផ្សេងទៀត តុលាការនឹងមិនចេញសេចក្ដីសម្រេចបង្កើតសុំកូនធម្មតាឡើយ។

ជាងនេះទៅទៀត អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចដាក់ពាក្យសុំបង្កើតសុំកូនធម្មតា ដោយយកអនីតិជនដែលនៅក្រោមអាណាព្យាបាលរបស់ខ្លួនមកធ្វើជាកូនសុំធម្មតាបាន។ ដូចគ្នាដែរ អ្នកអាណាព្យាបាលទូទៅក៏អាចដាក់ពាក្យសុំបង្កើតសុំកូនធម្មតា ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន ធ្វើជាកូនសុំបានដែរ។ នៅក្នុងស្ថានភាពបែបនេះ តុលាការនឹងអាចសម្រេចឱ្យបង្កើតសុំកូនធម្មតាបាន តែក្នុងករណីដែលមានការអនុវត្តត្រឹមត្រូវក្នុងការគ្រប់គ្រងថែរក្សា និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលក្នុងពេលកន្លងមក (មាត្រា១០២៥)។

**៣.២.២. ទម្រង់នៃពាក្យសុំ**

ចំពោះទម្រង់នៃពាក្យសុំនេះ មិនមានអ្វីខុសគ្នាពីទម្រង់នៃពាក្យសុំបង្កើតសុំកូនពេញលេញទេ ពោលគឺមានទម្រង់ដូចគ្នា។

**៣.២.៣. ស្ថាប័នទទួលពាក្យសុំ**

មានលក្ខណៈខុសគ្នាដាច់ស្រឡះ ចំពោះទីកន្លែងនៃការទទួលពាក្យសុំបង្កើតសុំកូននេះ។ ការដាក់ពាក្យសុំបង្កើតសុំកូនពេញលេញ គឺច្បាប់តម្រូវឱ្យធ្វើឡើងនៅតុលាការដែលស្ថិតនៅលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។ ប៉ុន្តែចំពោះការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាវិញ យោងតាមតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងបានចែងថា តុលាការដែលមានសមត្ថកិច្ចនៅក្នុងការសម្រេចឱ្យបង្កើតសុំកូនធម្មតាគឺ តុលាការនៃលំនៅឋានរបស់អ្នកដែលក្លាយជាកូនសុំ។

## ៣.៣. អានុភាពនៃសុំកូនធម្មតាចំពោះបុគ្គលភាព

ដោយសារតែសុំកូនធម្មតាមិនមានលក្ខណៈតឹងរឹងដូចសុំកូនពេញលេញ ដូច្នេះ លក្ខខណ្ឌផ្សេងៗដែលទាក់ទងនឹងករណីយកិច្ច និងសិទ្ធិក៏ងាយស្រួលក្នុងការទទួលយកផងដែរ។ ក្រោយពីការសុំកូនធម្មតាបានសម្រេចចូលជាស្ថាពរ នោះអានុភាពមួយចំនួនក៏បានកើតឡើងដែរ ដែលនៅក្នុងនោះមានដូចជា ការបង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម និងការបន្តញាតិភាពជាមួយឪពុកម្ដាយបង្កើត និងសិទ្ធិទទួលបានសន្តតិកម្ម និងករណីយកិច្ចរបស់ឪពុកម្ដាយបង្កើត និងឪពុកម្ដាយចិញ្ចឹម។

**៣.៣.១. អានុភាពចំពោះកូនសុំ**

- **ពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ៖** ញាតិភាពរវាងកូនសុំនិងឪពុកម្ដាយបង្កើតត្រូវបន្តអត្ថិភាពរហូត។
- **ពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ៖** អត្ថិភាពរបស់កូនសុំធម្មតាមានទទួលបានសន្តតិកម្ម ពីឪពុកម្ដាយកូនបង្កើត និងមានសិទ្ធិទាមទារនូវអាហារកាតព្វកិច្ចថែមទៀតផង។

### ៣.៣.២. អានុភាពចំពោះឪពុកម្តាយបង្កើត

- **ពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ៖** ទំនាក់ទំនងរវាងញាតិរបស់ឪពុកម្តាយបង្កើតនឹងកូនបង្កើតនៅតែបន្ត ហើយញាតិសាច់លោហិតរបស់កូនសុំធម្មតានោះនៅបន្តអត្ថិភាពដដែល[63]។
- **ពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ៖** ដោយទំនាក់ទំនងញាតិឪពុកម្តាយបង្កើត និងកូនបង្កើតនៅតែបន្តដូចនេះឪពុកម្តាយបង្កើតអាចផ្តល់សន្តតិកម្ម និងមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់កូន[64]។

### ៣.៣.៣. អានុភាពចំពោះឪពុកម្តាយចិញ្ចឹម

- **ពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ៖** ព្រមពេលជាមួយគ្នានេះ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិ លោហិតរបស់ឪពុកម្តាយចិញ្ចឹមត្រូវបានបង្កើតឡើង ដោយកូនសុំធម្មតាមានឋានៈដូចគ្នានឹងកូនបង្កើត គឺត្រូវទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម [65] ។ ហើយកូនសុំធម្មតាអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬអាចប្រើនាមត្រកូលរបស់ខ្លួនមុនបាន [66] ។ លើសពីប្រសិនបើកូនសុំជាអនីតិជន កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម។ ប៉ុន្តែក្នុងករណីដែលជាសុំកូនរបស់សហព័ទ្ធម្ខាងទៀត កូនសុំជាអនីតិជនត្រូវនឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹមស្ថិតក្រោមអំណាចមេបារួមរបស់សហព័ទ្ធទាំងសងខាង។
- **ពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ៖** ទំនាក់ទំនងញាតិត្រូវបានបង្កើតរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំកូនធម្មតាដូច្នេះសិទ្ធិផ្តល់និងទទួលបានសន្តតិកម្មក៏ត្រូវបានចាប់ផ្តើមដូចគ្នា ហើយសិទ្ធិទទួលបានអាហារកាព្វកិច្ចក៏ផ្តល់ឱ្យកូនសុំធម្មតាផងដែរ។

## ផ្នែកទី៤ ៖ ការកាត់កាល់សុំកូនធម្មតា

ខុសប្លែកពីការកាត់កាល់សុំកូនពេញលេញ សុំកូនធម្មតាអាចត្រូវកាត់កាល់តាមពីររបៀប ក៏ប៉ុន្តែការកាត់កាល់សុំកូនធម្មតានាំឱ្យមានអានុភាព ដូចជាការកាត់កាល់សុំកូនពេញលេញដែរ។

### ៤.១. លក្ខខណ្ឌនៃកាត់កាល់សុំកូនធម្មតា

ការកាត់កាល់ សំដៅដល់ការបោះបង់លែងរាប់អានតទៅទៀត គឺមានន័យថាបើមានពាក្យសុំកាត់កាល់សុំកូនធម្មតា តុលាការអាចសម្រេចឱ្យកាត់កាល់បានក្នុងករណីដែលភាគីទាំងសងខាងមានបំណងពិតប្រាកដ

[63] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៦ កថាខណ្ឌទី១។
[64] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៦ កថាខណ្ឌទី២។
[65] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៧។
[66] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៦ កថាខណ្ឌទី២។

មែន ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយនឹងកូន ដោយយោងតាមមាត្រា១០៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧[67]។

លើសពីនេះ បុគ្គលដែលអាចដាក់ពាក្យបណ្តឹងទាមទារឱ្យកាត់កាលបានលុះត្រាតែភាគីម្ខាងទៀតបានប្រព្រឹត្តដូចក្នុងបញ្ញត្តិនៃមាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី។

ការកាត់កាល់សុំកូនធម្មតាអាចធ្វើបានយ៉ាងងាយស្រួល កាលបើមានការព្រមព្រៀងរវាង ភាគីនៃសុំកូន ហើយនៅក្នុងករណីដែលភាគីម្ខាងនៃសុំកូនមានបំណងកាត់កាល់ជាឯកតោភាគីគាត់ត្រូវតែដាក់ពាក្យបណ្តឹង។

### ៤.១.១.ការកាត់កាល់សុំកូនធម្មតាតាមការព្រមព្រៀង

បន្ទាប់ពីរបបសុំកូនធម្មតាត្រូវបានបង្កើតឡើង ហើយភាគីនៃសុំកូនអាចព្រមព្រៀងគ្នា ដើម្បីកាត់កាល់សុំកូននេះបាន[68]។ ក្នុងករណីនេះ ភាគីទាំងសងខាងនៃសុំកូនត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់កូនសុំ។ តុលាការនឹងធ្វើការសម្រេចសេចក្តីដោយចេញជាដីកាសម្រេច យោងទៅតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិន មែនជាបណ្តឹង[69]។

ម្យ៉ាងវិញទៀត នៅក្នុងករណីដែលកូនសុំគឺជាអនីតិជន ពាក្យសុំព្រមព្រៀងកាត់កាល់ត្រូវ ធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់កំណត់របស់អនីតិជននោះ ក្រោយពេលកាត់កាល់។ ជាទូទៅ បុគ្គលដែលនឹងក្លាយទៅជាអ្នកតំណាងដែលច្បាប់ កំណត់របស់អនីតិជន គឺជាឪពុកម្តាយបង្កើតរបស់អនីតិជននោះតែម្តង។ ប៉ុន្តែ ប្រសិនបើឪពុកម្តាយបង្កើតរបស់អនីតិជនបានលែងលះគ្នា អ្នកទាំងពីរត្រូវពិភាក្សាគ្នាដើម្បីកំណត់ថា តើនរណានឹងក្លាយជាអ្នកមានអំណាចមេបាលើអនីតិជន ហើយបើការពិភាក្សាមិនអាចធ្វើបានទេ តុលាការជាអ្នកកំណត់ថាឱ្យឪពុកបង្កើត ឬម្តាយបង្កើតដែលនឹងក្លាយជាអ្នកមានអំណាចមេបាលើកូន[70]។

ក្នុងអត្ថន័យប្រហាក់ប្រហែលទៅនឹងការបង្កើតសុំកូនធម្មតាដែរ ក្រមរដ្ឋប្បវេណីតម្រូវឱ្យកូនសុំជាអនីតិជនដែលមានអាយុដល់១៥ ឆ្នាំ ផ្តល់ការយល់ព្រមទៅនឹងការកាត់កាល់នេះផងទើបបាន។ ក្រៅពីនេះ នៅពេលដែលអនីតិជនអាចបង្ហាញឆន្ទៈបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះផង ពាក់ព័ន្ធនឹងការកាត់កាល់សុំកូនធម្មតា[71]។

---

67 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣០។
68 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៨ កថាខណ្ឌទី១។
69 ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។
70 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៨ កថាខណ្ឌទី៣ និងទី៤។
71 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៨ កថាខណ្ឌទី២។

ចំពោះភាគីនៃឪពុកម្ដាយចិញ្ចឹមវិញ ក្រមរដ្ឋប្បវេណីបានតម្រូវឱ្យសហព័ទ្ធទាំងសងខាងដែលជាឪពុកម្ដាយចិញ្ចឹម តាមរយៈការដាក់ពាក្យសុំបង្កើតសុំកូនដោយសហការគ្នា ត្រូវដាក់ពាក្យសុំកាត់កាល់នេះជាមួយគ្នា លើកលែងតែសហព័ទ្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈខ្លួនបាន។

ក្រោយពីបានទទួលពាក្យសុំកាត់កាល់តាមការព្រមព្រៀងនេះ តុលាការត្រូវពិនិត្យមើលថា តើភាគីពិតជាមានឆន្ទៈក្នុងការរំលាយទំនាក់ទំនងសុំកូនដែរឬទេ ដើម្បីធ្វើការសម្រេចសេចក្ដី។

### ៤.១.២.ការកាត់កាល់សុំកូនធម្មតាតាមពាក្យបណ្ដឹងរបស់ភាគីម្ខាង

ផ្ទុយពីករណីខាងលើ ប្រសិនបើមិនអាចទទួលបានការព្រមព្រៀងក្នុងការស្នើសុំកាត់កាល់សុំកូនធម្មតាទេ ភាគីម្ខាងនៃសុំកូនធម្មតាអាចដាក់ ពាក្យបណ្ដឹងទាមទារកាត់កាល់សុំកូនធម្មតា បានដោយយោងទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល (មាត្រា៣ ចំណុច ឈ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ ក្នុងករណីនេះ តុលាការធ្វើ ការសម្រេចសេចក្ដី ដោយចេញជាសាលក្រម។

យោងតាមអត្ថន័យនៃមាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី ភាគីខាងឪពុកម្ដាយចិញ្ចឹមអាចដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់បានហើយភាគីខាងកូនសុំធម្មតាក៏អាចដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់បានដែរ[72]។

ប្រសិនបើកូនសុំ ជាអនីតិជននៅឡើយ អ្នកដែលនឹងក្លាយជាអ្នកតំណាងតាមច្បាប់កំណត់ របស់កូនសុំគឺជាអ្នកដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់នេះ។ ជាងនេះទៅទៀត បើកូនសុំបានដល់អាយុ ១៥ឆ្នាំ ហើយត្រូវតែមានការយល់ព្រមពីអនីតិជននោះផងទើបបាន[73]។

ក្នុងន័យដើម្បីការពារផលប្រយោជន៍របស់អនីតិជន ក្រមរដ្ឋប្បវេណីបានធ្វើការហាមឃាត់ ការដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់ពីសំណាក់ឪពុកម្ដាយចិញ្ចឹម ប្រសិនបើកូនសុំនៅជាអនីតិជននៅឡើយ (មាត្រា១០៣១ កថាខណ្ឌទី ២)[74]។

## ៤.២. មូលហេតុនៃការកាត់កាល់សុំកូនធម្មតា

ជាមួយគ្នានេះការទាមទារកាត់កាល់សុំកូនធម្មតាត្រូវតែមានមូលហេតុដូចដូចខាងក្រោម[75]៖

- បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត។
- បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬទទួលមរណភាព។
- បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលនាំឱ្យពិបាកក្នុងការបន្តសុំកូន។

## ៤.៣. អានុភាពនៃការកាត់កាល់សុំកូនធម្មតា

[72] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣១ កថាខណ្ឌទី៣។

[73] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៨ កថាខណ្ឌទី២ វាក្យខណ្ឌទី១។

[74] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣១ កថាខណ្ឌទី២។

[75] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣១។

អានុភាពនៃការកាត់កាល់សុំកូនធម្មតា មិនខុសប្លែកពីអានុភាពនៃការកាត់កាល់សុំកូនពេញលេញទេ ការកាត់កាល់សុំកូនធម្មតា មិនមានអានុភាពប្រតិសកម្ម (ភាពដើរថយក្រោយ) ឡើយបានសេចក្តីថាការកាត់កាល់មានអានុភាពបញ្ចប់សុំកូនធម្មតា គិតចាប់ពីពេលកាត់កាល់តទៅ។

ដូច្នេះទំនាក់ទំនងញាតិរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមត្រូវបញ្ចប់នៅពេលនោះ។ ក៏ប៉ុន្តែកូនសុំនៅតែអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមបាន (មាត្រា ១០៣២)[76]។

## ៤.៤. សិទ្ធិរបស់កូនសុំកូនធម្មតា

សិទ្ធិរបស់កូនសុំធម្មតា និងកូនសុំពេញលេញ គឺមានភាពស្រដៀងគ្នាបំផុត អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺសិទ្ធិរបស់កូនសុំធម្មតាហាក់មានច្រើនជាងកូនសុំពេញលេញ។ តើអ្វីដែលអាចឱ្យយើងសន្និដ្ឋានថា កូនសុំធម្មតាមានសិទ្ធិច្រើនជាងកូនសុំពេញលេញ? ដោយមូលហេតុថា កូនសុំធម្មតាមិនបានផ្តាច់ទំនាក់ទំនងញាតិពីឪពុកម្តាយបង្កើតនោះទេ ដូច្នេះកូនសុំធម្មតាអាចទទួលបានផលប្រយោជន៍ពីឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង។

### ៤.៤.១. សិទ្ធិប្រើប្រាស់នាមត្រកូលដែលខ្លួនពេញចិត្ត

នៅក្នុងការប្រើប្រាស់នាមត្រកូល កូនសុំធម្មតាមានសិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់ខ្លួនដែលមាននៅមុនពេលបង្កើតសុំកូនក៏បាន ឬប្រើប្រាស់នាមត្រកូលតាមឪពុកម្តាយចិញ្ចឹមក៏បានដែរ ពោលគឺដូចគ្នាទៅនឹងការសុំកូនពេញលេញដែរ[77]។

### ៤.៤.២. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹម

បើយើងក្រឡេកមើលទៅថាខណ្ឌទី១ ចំណុច(គ)[78] កូនសុំពេញលេញត្រូវផ្តាច់ទំនាក់ទំនងញាតិភាពពីឪពុកម្តាយបង្កើត ដូច្នេះគេអាចរស់ស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹមនៅក្នុងពេលដែលគេមិនទាន់ក្លាយជានីតិជន។

ប៉ុន្តែចំពោះកូនសុំធម្មតាវិញ គេនៅតែអាចបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត ដូច្នេះច្បាប់បានផ្តល់សិទ្ធិគេស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង។

### ៤.៤.៣. សិទ្ធិទទួលបានអាហារកាតព្វកិច្ច

កូនគ្រប់រូបមិនថា ជាកូនបង្កើត ឬជាកូនចិញ្ចឹមនោះទេ សុទ្ធតែមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចពីអាណាព្យាបាលរបស់ខ្លួន។

---

[76] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣២។

[77] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០១៥ កថាខណ្ឌទី២។

[78] ចំណុច(គ) សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម។

ហេតុនេះហើយ យើងអាចទាញពន្យល់បានថា នៅពេលបង្កើតសុំកូនធម្មតា កូនសុំបានក្លាយជាកូនរបស់ឪពុកម្តាយចិញ្ចឹម ប៉ុន្តែកូននោះនៅតែជាកូនរបស់ឪពុកម្តាយបង្កើតដដែល ដូច្នេះកូនសុំនោះអាចមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចពីសំណាក់ឪពុកម្តាយទាំងសងខាង ពោលគឺទាំងឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹម[79]។

### ៤.៤.៤. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម

យើងបានដឹងពីខាងលើហើយថា សន្តតិកម្មជាការផ្ទេរសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់។ ចំពោះកូនសុំពេញលេញ ដែលបានផ្តាច់ទំនាក់ទំនងញាតិពីឪពុកម្តាយបង្កើតហើយនោះ គេអាចទទួលបានសិទ្ធិធ្វើ និងទទួលសន្តតិកម្មតែពីឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ[80]។

ផ្ទុយទៅវិញ ចំពោះកូនសុំធម្មតា គឺគេទទួលបានផលប្រយោជន៍ច្រើនជាងកូនសុំពេញលេញត្រង់ថា គេនៅបន្តទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត ដូច្នេះចំពោះសិទ្ធិធ្វើនិងទទួលសន្តតិកម្ម គេអាចមានសិទ្ធិធ្វើ និងទទួលសន្តតិកម្មពីឪពុកម្តាយបង្កើត និងញាតិលោហិតបង្កើតផង និងឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់គាត់ផង។

### ៤.៤.៥. សិទ្ធិប្តឹងទាមទារមរតក

ចំពោះសិទ្ធិនេះ ទាំងកូនសុំពេញលេញ និងកូនសុំធម្មតា សុទ្ធតែបានទទួលបាន ព្រោះថាសិទ្ធិនេះកូនសុំអាចធ្វើបាន នៅពេលដែលខ្លួនពុំទទួលបានមរតក ដែលជាចំណែករបស់ខ្លួន។ ដូច្នេះចំពោះកូនសុំធម្មតា គេអាចមានសិទ្ធិប្តឹងទាមទារមរតកពីឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ក្នុងករណីដែលគេត្រូវបានកាត់ផ្តាច់ចេញពីមរតកដោយពុំមានហេតុផលសមស្របណាមួយ[81]។

- **កំណត់ចំណាំ៖**

ការសុំកូនធម្មតាមិនមែនជាការផ្តាច់ទំនាក់ទំនងគតិយុត្ត ជាមួយឪពុកម្តាយបង្កើតនោះទេ ដូច្នេះ មិនចាំបាច់លាក់បាំងសាធារណៈនោះទេ ហេតុនេះនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ទាមទារឱ្យមានការសរសេរដូចគ្នាទៅនឹងកូនបង្កើតនោះដែរ នៅលើទំព័រនៃបញ្ជីអត្រានុកូលដ្ឋានដើម និងសំបុត្រកំណើតដើមរបស់កូននោះ។

[79] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៦ កថាខណ្ឌទី២។
[80] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៦ កថាខណ្ឌទី១។
[81] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០២៦ កថាខណ្ឌទី១។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើរួចហើយ ក្រុមខ្ញុំបាទសង្កេតឃើញការអនុវត្តសុំកូនក្រោមច្បាប់នៅព្រះរាជាណាចក្រកម្ពុជារបស់យើងពិតជាមានសារសំខាន់ណាស់ ព្រោះថាដើម្បីឱ្យមនុស្សម្នាក់ក្លាយជាធនធានល្អនៅក្នុងសង្គមបាន លុះត្រាតែជននោះទទួលបានការចិញ្ចឹមបីបាច់រក្សាយ៉ាងយកចិត្តទុកដាក់ ទទួលបានការអប់រំ ការហ្វឹកហ្វឺនត្រឹមត្រូវ និងការទូន្មានពីក្រុមគ្រួសារ សាច់ញាតិ បងប្អូន និងមនុស្សនៅជុំវិញខ្លួន។ តួយ៉ាងនៅក្នុងច្បាប់កម្ពុជារបស់យើងបានបែងចែកនូវរបបសុំកូន ក្នុងករណីសហព័ទ្ធណាដែលគ្មានកូន និងចង់បានកូនមកចិញ្ចឹមដើម្បីទទួលមរតក និងអាចថែរក្សាខ្លួនពេលចាស់ជរាដែលការសុំកូននេះអាចនឹងត្រូវផ្តាច់ទំនាក់ទំនងសាច់ញាតិបង្កើត និងអាចបន្តសាច់ញាតិបង្កើត។ យ៉ាងណាមិញ ប្រសិនការស្នើសុំស្ថិតក្នុងរបបសុំកូនពេញលេញ ឬសុំកូនធម្មតាក៏ដោយ នាំឱ្យយើងយល់ដឹងពីគោលបំណង ឬវត្ថុបំណងសំខាន់នៃរបបនៃការសុំកូននោះគឺ ដើម្បីបំពេញតម្រូវការទំនាក់ទំនងក្នុងជីវិតគ្រួសារ បញ្ហាមនុស្សធម៌ ជាពិសេសរក្សា និងផ្តល់ឧត្តមប្រយោជន៍ដល់កុមារ ធានាការរស់នៅ និងអនាគតត្រឹមត្រូវសម្រាប់កុមារ ឬកូនសុំ។ ហេតុដូច្នេះដើម្បីបង្កើតការសុំកូន មិនថាជាការសុំកូនពេញលេញ ដែលផ្តាច់ទាំងស្រុងនូវទំនាក់ទំនងញាតិចាស់ ឬសុំកូនធម្មតាដែលនៅរក្សាទំនាក់ទំនងញាតិចាស់នោះទេ គឺត្រូវឆ្លងកាត់លក្ខខណ្ឌច្បាប់ និងការវាយតម្លៃពីអាជ្ញាធរពាក់ព័ន្ធជាពិសេស គឺស្ថាប័នតុលាការ។ ក្នុងកិច្ចនីតិវិធីក្នុងការសុំកូនយើងឃើញមានលក្ខខណ្ឌចាំបាច់រួមមាន គុណសម្បត្តិរបស់ឪពុក ម្តាយចិញ្ចឹម លក្ខខណ្ឌឪពុកម្តាយបង្កើត និងលក្ខខណ្ឌនានារបស់កូនចិញ្ចឹម។ លក្ខខណ្ឌទាំងអស់នេះ គឺជាការចាំបាច់ក្នុងការបង្កើតការសុំកូនដើម្បីធានាថា កូនដែលត្រូវបានសុំ អាចរស់នៅដោយសុខុមាលភាពទាំងរូបកាយ និងការអប់រំ។

អ្វីដែលសំខាន់ដែលជាផលកើតចេញពីការសុំកូននោះ គឺអានុភាពរបស់វា។ នៅពេលដែលអានុភាពនៃការសុំកូនចាប់ផ្តើមវានឹងបង្កើតនូវទំនាកទំនងញាតិរវាងកូនសុំ នឹងឪពុកម្តាយចិញ្ចឹម រួមទាំងញាតិរបស់ឪពុកម្តាយចិញ្ចឹមផងដែរ ហើយថាកូនចិញ្ចឹមច្បាប់សន្មត់ទុកស្មើ នឹងកូនបង្កើតក្នុងទំនាក់ទំនងគតិយុត្ត និយាយឱ្យចំកូនចិញ្ចឹមមានសិទ្ធិ និងកាតព្វកិច្ចដូចគ្នានឹងកូនបង្កើតដែល ដូចជាសន្តិតកម្ម ជម្រើសនៃការប្រើប្រាស់នាមត្រកូលជាអាទិ៍។

ទោះបីជាការរបបសុំកូនធ្វើឱ្យកើតឡើងនូវទំនាក់ទំនងគតិយុត្តញាតិថ្មី រវាងកូនចិញ្ចឹម និងឪពុកម្តាយចិញ្ចឹម និងញាតិរបស់ឪពុកម្តាយចិញ្ចឹម ឬហៅថាញាតិតាមច្បាប់កំណត់ក៏ដោយ ក៏ទំនាក់ទំនងនេះអាចត្រូវបានបញ្ចប់ប្រសិនបើក្នុងទំនាក់នងនេះត្រូវបានរកឃើញ ឬលេចឡើតនូវស្ថានភាពណាមួយដែលខុសពីស្មារតីនៃការសុំកូន ដូចជាការធ្វើទុក្ខបុកម្នេញលើកូនចិញ្ចឹម ឬការដាក់ឱ្យកូនចិញ្ចឹមស្ថិតក្នុងភាពគ្រោះថ្នាក់។ល។ នោះភាគីពាក់ព័ន្ធអាចស្នើសុំរំលត់ការសុំកូនវិញបាន ដែលវាជាសិទ្ធិរបស់ កូនចិញ្ចឹម ឪពុកម្តាយបង្កើតអាជ្ញាធរពាក់ព័ន្ធដើម្បីស្នើទៅតុលាការដើម្បីរំលត់របបនៃការសុំកូនបាន បើវាពិតជាប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់កូនចិញ្ចឹម

ពិតប្រាកដមែន។ ប៉ុន្តែទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម ក៏ច្បាប់ផ្តល់សិទ្ធិឱ្យឪពុកម្តាយចិញ្ចឹមផ្តាច់ទំនាក់ទំនងញាតិបានដែរ ក្នុងករណីកូនចិញ្ចឹមដែលជានីតិជននោះ ក្លាយជាមនុស្សពិបាកប្រៀនប្រដៅ ឬបំផ្លិចបំផ្លាញគ្រួសារ តាមរយៈការកាត់កាល។

សរុបមក ការសិក្សាពីការអនុវត្តសុំកូនក្រោមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ផ្តល់ឱ្យយើងនូវចំណេះសំខាន់ចំនួនទាក់ទងនឹងការអនុវត្តសុំកូនក្រោមច្បាប់នៅព្រះរាជាណាចក្រកម្ពុជានេះ គឺវត្ថុបំណងនៃការសុំកូន លក្ខខណ្ឌ អានុភាព និងការបញ្ចប់ទៅវិញនៃរបបសុំកូន៕

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការបំភ្លឺ បកស្រាយវែកញែក និងការសន្និដ្ឋានរួចមក ក្នុងនាមខ្ញុំបាទជានិស្សិត ជាទំពាំងស្នងឬស្សី ក៏ជាធនធានមនុស្សសម្រាប់ប្រទេសជាតិ យើងខ្ញុំក៏សូមផ្តល់នូវអនុសាសន៍ដែលជាគោលគំនិតតូចមួយ ក្នុងការចូលរួមដើម្បីការពារទៅដល់ការសុំកូន និងការពារកុំឱ្យមានការរំលោភបំពានលើកុមារដូចខាងក្រោមៈ

- ឪពុកម្តាយ ឬអាណាព្យាបាលកូន គួរយល់ថាកូនម្នាក់ដែលខ្លួនបង្កើតចេញពីសាច់ ធ្លាប់ចិញ្ចឹមបីបាច់ បើទោះបីខ្លួនគ្មានលទ្ធភាពចិញ្ចឹម ហើយចង់ផ្តល់កូនឱ្យទៅនរណាម្នាក់គឺតែងចង់ឱ្យកូនបាននៅជាមួយមនុស្សល្អ ដូច្នេះហើយគួរតែផ្តល់កូនតាមផ្លូវច្បាប់ ទើបមានច្បាប់ជួយការពារបាននៅពេលមានការឆបោក ឬធ្វើបាបទៅលើកុមារ។
- គួរយកចិត្តទុកដាក់ លើក្របខណ្ឌគតិយុត្តដែលនៅមានចន្លោះខ្វះខាត ជាអាទិ៍ មិនទាន់មានប្បញ្ញត្តិស្តីពីការកាត់កាល់នៃសុំកូនអន្តរប្រទេស ឬការទទួលយកកុមារត្រឡប់មកវិញសោះឡើយ ក្នុងករណីណាមួយមានបទល្មើសកើតឡើងចំពោះកុមារដែលបានសុំយកទៅចិញ្ចឹមនៅប្រទេសអចិន្ត្រៃយ៍។
- អាជ្ញាធរមានសមត្ថកិច្ច គួរតែចុះផ្សព្វផ្សាយអំពីច្បាប់ការការពារដល់ប្រជាពលរដ្ឋតាមតំបន់ឱ្យបានទូលាយ និងដាក់ទោសជាកំហិតចំពោះជនល្មើសកុំឱ្យរួចខ្លួន។
- រាជរដ្ឋាភិបាលកម្ពុជាគួរតែនឹងចេញនូវលិខិតទទួលស្គាល់ជាសាធារណៈ ចំពោះកំហុសឆ្គងដែលអាជ្ញាធររដ្ឋបាលបានប្រព្រឹត្តពីអតីតកាល ការទទួលស្គាល់កំហុសចំពោះជនរងគ្រោះទាំងអស់ និងការអញ្ជើញក្រុមគ្រួសារដែលប៉ះពាល់ឱ្យមកប្រាប់ពីរឿងរ៉ាវរបស់អ្នកទាំងនោះ និងស្វែងរកសំណងព្យសនកម្ម។
- រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលនៃប្រទេសដែលទទួលកុមារ គួរតែបង្កើតគណៈកម្មាធិការស៊ើបអង្កេតពិសេសមួយ ដើម្បីជួយដល់ក្រុមគ្រួសារកម្ពុជាដែលរងគ្រោះដោយសកម្មភាពសុំកូនក្លែងបន្លំ ក្នុងការស្វែងរកទីតាំងរស់នៅរបស់កូនៗទាំងនោះ និងជួយភ្ជាប់ទំនាក់ទំនងឡើងវិញរវាងឪពុកម្តាយ និងកូន។

យោងតាមគំនិតស្តួចស្តើងខាងលើ យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាអាចជាចំណែកតូចមួយក្នុងការជួយដល់សិស្សនិស្សិតដែលសិក្សាស្វែងយល់ ឱ្យកាន់តែមានការយល់ច្បាស់ និងកាន់ស៊ីជម្រៅថែមមួយកម្រិតទៀត ក៏ដូចជាជួយដល់ប្រជាជនឱ្យកាន់តែមានការយល់ដឹង និងប្រុងប្រយ័ត្នលើការផ្តល់ ឬការសុំកូន។

# ឯកសារយោង

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។
- អនុសញ្ញាស្តីពីសិទ្ធិកុមារ, សេចក្តីសម្រេចចិត្ត លេខ ៤៤/២៥, ២០ វិច្ឆិកា ១៩៨៩។


## ២. សៀវភៅ ទស្សនាវដ្តី និងឯកសារផ្សេងៗទៀត


- ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, *យល់ដឹងផ្នែកច្បាប់៖ ការសុំកូន* (២២ មេសា ២០២០), https://ciclg.com/kh/article/72 ។
- ចាំង ស៊ីណាត, *នីតិរដ្ឋប្បវេណីស្តីពីសុំកូន* (រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឧសភា ២០១៥)។
- ទេព បូផល, សិក្ខាសាលាស្តីពីបុគ្គភាព និងអំណាចមេបា (បទបង្ហាញស្តីពីសុំកូន), ៣០ ឧសភា ២០១៥។
- ប៉ុល ម៉ាឌីលីន និង ឯល សុខគ្រី, *សុំកូនពេញលេញ,* សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០២០។
- មនោ កែវគតិយុត្តិ, *បញ្ហាចោទសុំកូនក្នុងប្រទេស,* សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៧។
- *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧)។
- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយលិខិតបទដ្ឋាននានារបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស, ២៦ កុម្ភៈ ២០១៤។
- ហ៊ុយ សុខលីន, *សុំកូនអន្តរប្រទេស,* សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០២០។
- អ៊ុំ ប៉ូលី, *នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប)* (ភ្នំពេញ៖ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ២០១១)។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

ដីកាសម្រេចបង្កើតកូនស៊ុំ

*ឧបសម្ព័ន្ធទី១ : ដីកាសម្រេចបង្កើតកូនសុំ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង** .....

**ដីកាសម្រេចលេខ:** ...............
ថ្ងៃទី ...... ខែ...... ឆ្នាំ ......

## ដីកាសម្រេចបង្កើតសុំកូនពេញលេញ

យើង ................................. ចៅក្រមនៃសាលាដំបូង ..................។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០០៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ ៖**

១. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

២. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

**ឪពុកម្តាយបង្កើត ៖**

១. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

២. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

**កូនឈ្មោះ** ៖ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ** ៖ បង្កើតសុំកូនពេញលេញរវាងឈ្មោះ **ក.** ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្តាយចិញ្ចឹម និង ឈ្មោះ **គ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ........ ដែលមានឋានៈជាកូនសុំ។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ភេទប្រុស កើតនៅថ្ងៃទី .... ខែ ..... ឆ្នាំ.......... ដោយមានសំបុត្រកំណើតលេខ .... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ជាប្តី និង ឈ្មោះ **ខ.** ភេទស្រី កើតថ្ងៃទី ... ខែ ... ឆ្នាំ ... គឺជាសហព័ទ្ធនឹងគ្នា ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ។ ឈ្មោះ **គ.** ភេទ ... កើតនៅថ្ងៃទី .... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ **ក.** មានអាយុ ... និង ឈ្មោះ **ខ.** មានអាយុ ... ពោលគឺមានអាយុលើសឈ្មោះ **គ.** លើសពី ២០ ឆ្នាំ។ ដូច្នេះ អ្នកដាក់ពាក្យសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនពេញលេញ តាមមាត្រា ១០០៨ មាត្រា ១០០៩ និង មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី។

២. ឈ្មោះ **ង.** និង ឈ្មោះ **ច.** ត្រូវជាឪពុកម្តាយបង្កើតរបស់ឈ្មោះ **គ.** បានយល់ព្រមឱ្យឈ្មោះ **គ.** ទៅឈ្មោះ **ក.** និង ឈ្មោះ **ខ.** ចិញ្ចឹមធ្វើជាកូនសុំពេញលេញ ដោយសារតែពួកខ្លួនមិនមានលទ្ធភាពសមរម្យក្នុងការចិញ្ចឹមបីបាច់ថែរក្សាឈ្មោះ **គ.**។

៣. បន្ទាប់ពីឈ្មោះ **ក.** និង ឈ្មោះ **ខ.** បានសាកល្បងចិញ្ចឹមឈ្មោះ **គ.** អស់រយៈពេល ... កន្លងមក ឃើញថា ឈ្មោះ **ក.** និង ឈ្មោះ **ខ.** បានរស់នៅចុះសម្រុងជាមួយនឹងឈ្មោះ **គ.**។

៤. មានស្ថានភាពគ្រប់គ្រាន់ដែលជាមូលដ្ឋានក្នុងការបង្កើតសុំកូនពេញលេញ សមស្របទៅតាមផលប្រយោជន៍កូន។

៥. យោងតាមមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

# សេចក្តីសម្រេចបញ្ចប់

១. បង្កើតសម្ពុំកូនពេញលេញ រវាងឈ្មោះ **ក.** ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ...... ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្តាយចិញ្ចឹម និង ឈ្មោះ **គ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង** ......

**ដីកាសម្រេចលេខ:** ...............
ថ្ងៃទី ...... ខែ...... ឆ្នាំ .......

# ដីកាសម្រេចបង្កើតសុំកូនធម៌តា

យើង ................................ ចៅក្រមនៃសាលាដំបូង ..................។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/ ០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០២០ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ** ៖

១. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

២. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ** ៖ បង្កើតសុំកូនធម្មតារវាងឈ្មោះ **ក.** ភេទ ...... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ដែលមានឋានៈជាម្តាយចិញ្ចឹម និង ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

### សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ជាស្ត្រីមេម៉ាយ កើតនៅថ្ងៃទី .... ខែ ..... ឆ្នាំ.......... ដោយមានសំបុត្រកំណើតលេខ .... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ពោលគឺមានអាយុ ..... បានព្រមព្រៀងបង្កើតសុំកូនធម៌តា ជាមួយនឹងឈ្មោះ **ខ.** នៅ លីវ ដែលកើតនៅថ្ងៃទី .... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ **ខ.** មានអាយុតិចជាងអ្នកដាក់ពាក្យសុំឈ្មោះ **ក.** ហើយក៏មិនមែនជាបុព្វញាតិរបស់អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ដែរ។

២. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** និង អ្នកដាក់ពាក្យសុំឈ្មោះ **ខ.** មានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងជាម្ដាយ និងកូន។

៣. អ្នកដាក់ពាក្យសុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនធម៌តាបាន តាមមាត្រា ១០២០ នៃក្រមរដ្ឋប្បវេណី។

៤. យោងតាមមាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ប្រាក់ប្រដាប់ក្ដីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## សេចក្ដីសម្រេចបញ្ចប់

១. បង្កើតសុំកូនធម៌តា រវាងឈ្មោះ **ក.** ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ដែលមានឋានៈជាម្ដាយចិញ្ចឹម និង ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

# ឧបសម្ព័ន្ធទី២

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

***ឧបសម្ព័ន្ធទី២ : ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧***

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

# ផ្នែកទី ២

# សុំកូន

## កថាភាគទី ១

## សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.-** អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.-** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.-** ការយល់ព្រមរបស់ឪពុកម្ដាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្ដាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្ដាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត ហើយយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.-** រំឮងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.-** ការបញ្ចប់ទំនាក់ញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្ដាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្ដាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.–** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

**មាត្រា ១០១៦.–** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាពីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.–** អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.–** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្ដីពីសុំកូនឡើយ ។

**មាត្រា ១០១៩.–** សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្ដីពីសុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

## កថាភាគទី ២

## សុំកូនធម្មតា

**មាត្រា ១០២០.–** ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាច

មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ១០២១.-** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុកឬម្ដាយចិញ្ចឹមមានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២២.-** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២៣.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

**មាត្រា ១០២៤.-** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជន

នោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន បើឪពុកម្ដាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្ដាយ ដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតសុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០២៥.-** សុំកូនរវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន មកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនាផ្លូវចំណូលចំណាយក្នុងការគ្រប់គ្រង ។

**មាត្រា ១០២៦.-** អានុភាពនៃសុំកូនធម្មតា ចំពោះបុត្តភាព

១-ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់

អាហារកាតព្វកិច្ច ។

**មាត្រា ១០២៧.-** អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំ ជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និង សហព័ទ្ធនោះ ។

**មាត្រា ១០២៨.-** ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបញ្ចេញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្ដាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្ដាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្ដាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា នៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

**មាត្រា ១០២៩.–** ការកាត់កាល់រវាងប្តីប្រពន្ធដែលបានសុំកូនដោយសហការ និង កូនសុំជាអនីតិជន

ក្នុងករណីដែលប្តីប្រពន្ធដែលបានសុំកូនដោយសហការគ្នា ជាឪពុកម្តាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្តីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្តីប្រពន្ធណាម្នាក់មិនអាចបង្ហាញឆន្ទៈរបស់ខ្លួន ។

**មាត្រា ១០៣០.–** ការវិនិច្ឆ័យអំពីការកាត់កាល់ស៊ុំកូនធម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់ស៊ុំកូនបានលុះត្រាតែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ។

**មាត្រា ១០៣១.–** មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃស៊ុំកូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ-បើមិនច្បាស់ ក្នុងរយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឱ្យមានការពិបាកក្នុងការបន្តស៊ុំកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនពេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្តាយចិញ្ចឹម ។

**មាត្រា ១០៣២.-** អានុភាពនៃការកាត់កាល់សុំកូនពេញ

១-អានុភាពទាំងឡាយនៃសុំកូនពេញ ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.-** ការចុះបញ្ជីនៃសុំកូនពេញ និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតសុំកូនពេញ ត្រូវសរសេរការបង្កើតសុំកូនពេញ នៅលើរបាំងទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

# ឧបសម្ព័ន្ធទី៣

ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

ឆ្នាំ ទី ១០ លេខ ៥៨ សប្តាហ៍ទី ១ ថ្ងៃ ទី ០៨ ខែ សីហា ឆ្នាំ ២០១០ រាជកិច្ច ទំព័រ ៦២៥០

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅនៃច្បាប់នេះ**

ច្បាប់នេះមានគោលដៅបញ្ញត្តនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ២.- គោលបំណងនៃច្បាប់នេះ**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ**

១- ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

២- ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

៣- ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្តីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

## ជំពូកទី ២
## តុលាការ
### ផ្នែកទី ១
### សមត្ថកិច្ចសាលាជម្រះក្តី

**មាត្រា ៤.- តុលាការដែលមានសមត្ថកិច្ច**

១- រឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ។

២- សមត្ថកិច្ចសាលាជម្រះក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយយកពេលដាក់ពាក្យសុំ ។

## មាត្រា ៥.- ការកំណត់តុលាការដែលមានសមត្ថកិច្ច

១- ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្ដីបាន ដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្ដីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ ។

២- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្ដឹងឧបាស្រ័យបានឡើយ ។

## មាត្រា ៦.- ការចាត់ចែងរឿងក្ដីខុសសមត្ថកិច្ច

១- ប្រសិនបើតុលាការយល់ឃើញថា រឿងក្ដីណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្ដីនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។

២- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលដាក់ពាក្យសុំនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

## មាត្រា ៧.- សមត្ថកិច្ចជាអាទិភាព និង ការផ្ទេរ

១- ក្នុងករណីមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្ដីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្ដីនោះ ត្រូវមានសមត្ថកិច្ច ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យដើម្បីចាត់ចែងរឿងក្ដី តុលាការអាចផ្ទេររឿងក្ដីនោះទៅតុលាការផ្សេងដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

៣- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ។

ROYAUME DU CAMBODGE • PALAIS ROYAL

Kol

## មាត្រា ៨.- ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

## មាត្រា ៩.- បណ្តឹងជំទាស់

១- ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

## មាត្រា ១០.- អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍

១- ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឲ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២- តុលាការដែលទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានឡើយ ។

៣- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ រឿងក្តីនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរចាត់ការតាំងពីដើម ។

៤- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរ ត្រូវបញ្ជូនសំណុំរឿងអំពីរឿងក្តីនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

# ផ្នែកទី ២
# រចនាសម្ព័ន្ធនៃតុលាការ

## មាត្រា ១១.- ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

១- នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២- ចំពោះរឿងក្តីដែលតុលាការយល់ឃើញថា គួរតែត្រូវបានវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃជនពាក់ព័ន្ធ និង បញ្ហាផ្សេងទៀត ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

ROYAUME DU CAMBODGE SECRETARIAT DU PALAIS ROYAL

Kol

៣- ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ ( បី ) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៤- ដីកាសម្រេចឲ្យវិនិច្ឆ័យ និង ជម្រះក្ដីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយយោងតាមកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

## មាត្រា ១២.- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវធ្វើជាសាធារណៈទេ ។

២- ការពិភាក្សាត្រូវបានបើក និងដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣- ចៅក្រមម្នាក់ៗ ត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤- ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិត្រូវរក្សាទុកជាសម្ងាត់ ។

## មាត្រា ១៣.- ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។

២- ចៅក្រមម្នាក់ៗ ក្នុងក្រុមប្រឹក្សាជំនុំជម្រះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

# ផ្នែកទី ៣

# ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្ដឹងជិតចិត្ត និង ការដកខ្លួន

## មាត្រា ១៤.- ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្ដឹងជិតចិត្ត និង ការដកខ្លួនរបស់ចៅក្រម ជាអាទិ៍

១- ព្រោតិតិពីការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្ដឹងជិតចិត្ត និងការដកខ្លួនរបស់ចៅក្រម

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

### មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ
គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ
លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

## មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី) ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឲ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

## មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

## មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

# ជំពូកទី ៥
# ការវិនិច្ឆ័យ

## មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។